# រឿងបងប្អូនស្រីពីរនាក់ ច្រណែននឹងប្អូនស្រីពៅ

ព្រះនាងសេហេរ៉ាសាធ ដោយពុំទាន់ដឹងច្បាស់ថា តើព្រះបាទស៊ុលតង់នឹងសម្លាប់នាង ឬក៏ទុកជីវិតនាងឱ្យគង់នៅ ក៏ចាប់និយាយរឿងថ្មីមួយទៀតទូលព្រះអង្គ ដើម្បីបន្លប់ព្រះអង្គកុំឱ្យទ្រង់នឹកតែទៅការសម្លាប់ចោលពេក មានសេចក្ដីដូចតទៅនេះ ÷

បពិត្រព្រះករុណាថ្លៃវិសេស កាលដើមឡើយមានព្រះអង្គម្ចាស់ប្រទេសពែរ្សមួយព្រះអង្គព្រះនាមកូរូសា ។ ព្រះអង្គម្ចាស់អង្គនេះកំពុងចាប់ផ្ដើមចង់ដឹងកិច្ចការផ្សេងៗក្នុងលោក ប៉ុន្តែព្រះអង្គច្រើនសព្វព្រះទ័យយាងដើរផ្សងព្រេងតែនៅវេលាយប់ គឺទ្រង់ស្លៀកពាក់ក្លែងព្រះអង្គមាននាយទាហានជំនិតមួយតាមដង្ហែផង ស្លៀកពាក់ក្លែងខ្លួនដូចជាព្រះអង្គដែរ ។ វេលាមួយព្រះអង្គទ្រង់យាងកាត់តាមសង្កាត់នៃទីក្រុង ព្រះអង្គទ្រង់បានទតឃើញវត្ថុដ៏ចម្លែកៗជាច្រើន ដែលខ្ញុំម្ចាស់ពុំអាចយកមកនិទានទូលព្រះអង្គក្នុងល្ងាចនេះ ឱ្យបានចប់ទាំងអស់តែម្ដងទេ ប៉ុន្តែខ្ញុំសង្ឃឹមថា ព្រះអង្គនឹងទ្រង់បានព្រះសណ្ដាប់យ៉ាងរីករាយ នូវរឿងមួយដែលកើតឡើងនៅពេលដែលព្រះមហាក្សត្រអង្គនោះ យាងចេញទតទីក្រុងនៅគ្រាជាដំបូងបង្អស់ នៅពេលពីរ-បីថ្ងៃ



បន្ទាប់ពីព្រះអង្គបានទ្រង់ឡើងសោយរាជសម្បត្តិជំនួសបិតាព្រះអង្គដែលទ្រង់សោយទិវង្គតទៅក្នុងព្រះជន្មាយុដ៏ចាស់ជរាជាទីបំផុត។ បិតាព្រះអង្គម្ចាស់មុននឹងទ្រង់សោយទិវង្គតទៅ បានប្រគល់ដែនដីប្រទេសពែរ្សថ្វាយមកព្រះអង្គម្ចាស់ទុកជាមរតក ។

បន្ទាប់ពីពិធីធ្វើបុណ្យរាជាភិសេក នឹងបន្ទាប់ពីពិធីបូជាព្រះបរមសព ព្រះករុណាជាអម្ចាស់លើត្បូងមក ព្រះចៅកូរូសា ជាព្រះបាទស៊ុលតង់ថ្មី ដើម្បីនឹងបានជ្រាបនូវកិច្ចការផ្សេងៗផ្ទាល់ព្រះអង្គ ព្រះអង្គក៏យាងចេញពីព្រះបរមរាជវាំងជាមួយលោកនាយករដ្ឋមន្ត្រី ស្លៀកពាក់ក្លែងកាយដូចជាព្រះអង្គដែរ នៅវេលាល្ងាចមួយ ពេលម៉ោងពីរយប់។ លុះយាងទៅដល់ក្នុងសង្កាត់មួយដែលមានតែប្រជាជនតូចតាចរស់នៅ, ព្រះអង្គទ្រង់ព្រះសណ្ដាប់ឮគេនិយាយគ្នាយ៉ាងខ្លាំងៗ ។ ព្រះអង្គក៏ទ្រង់យាងចូលទៅជិតផ្ទះដែលលេចឮសម្រែកនោះចេញមក, ។ រួចកាលបើព្រះអង្គទតតាមប្រហោងទ្វារទៅ ទ្រង់ក៏បានឃើញពន្លឺនឹងបងប្អូនស្រីបីនាក់អង្គុយនៅលើកៅអីវែង កំពុងជជែកគ្នាក្រោយពីញុំាបាយរួចមក។ កាលបើព្រះអង្គបានព្រះសណ្ដាប់សំដីស្ត្រីដែលចាស់ជាងគេទៅ ព្រះអង្គក៏ទ្រង់ជ្រាបថា ប្រធាននៃរឿងដែលគេជជែកគ្នានោះគឺ “សេចក្ដីប្រាថ្នា” ។ នារីជាបងបង្អស់ពោលថា : “សេចក្ដីប្រាថ្នារបស់អញគឺចង់បានអ្នកធ្វើនំប៉ុងថ្វាយព្រះរាជាធ្វើជាស្វាមី នៅពេលនោះអញនឹងស៊ីនំប៉ុងដ៏ឆ្ងាញ់នោះឱ្យឆ្អែតឆ្អន់ ដែលគេអាចហៅម្យ៉ាងទៀត

ថា នំប៉័ងព្រះបាទស៊ុលតង់” ។ ដូច្នេះ ចាំមើលតើមានបំណងអ្នកណាប្រសើរជាងអញទេ ។

- នារីជាប្អូនបន្ទាប់ក៏និយាយថា សេចក្តីប្រាថ្នារបស់ខ្ញុំ គឺចង់បានចៅហ្វាយនៃនាយពិសេសព្រះរាជាធ្វើជាប្តី នៅពេលនោះខ្ញុំនឹងញុំាម្ហូបសាច់ឆ្ងាញ់ៗ ហើយដោយខ្ញុំជឿជាក់ថា នំប៉័ងព្រះបាទស៊ុលតង់នឹងមាននៅក្នុងប្រាសាទឥតខ្វះឡើយ ដូច្នេះ ខ្ញុំក៏នឹងបាននំប៉័ងញុំាឥតខ្វះឡើយ ។ បងឃើញទេ សេចក្តីប្រាថ្នារបស់ខ្ញុំប្រសើរជាងសេចក្តីប្រាថ្នារបស់អ្នកបង ។

ចំណែកនាងពៅវិញ, ដែលមានរូបសម្បត្តិដ៏ល្អក្រៃលែង ហើយជាស្ត្រីប្រកបដោយគំនិតវៀងវៃជាងបងៗផង នាងបានពោលដូច្នេះថា “ចំណែកខ្ញុំ, ខ្ញុំមិនប្រាថ្នាអ្វីខ្លីបន្តិចដូច្នេះទេ ខ្ញុំប្រាកដជាប្រាថ្នាឱ្យបានខ្ពស់ជាងនេះហើយ បំណាច់យើងខំជជែកពីសេចក្តីប្រាថ្នា ។ ដូច្នេះខ្ញុំនឹងប្រាថ្នាឱ្យបានទៅជាមហេសីព្រះបាទស៊ុលតង់ ហើយសុំប្រាថ្នាឱ្យមានព្រះរាជបុត្រមួយ មានសក់មួយចំហៀងជាមាសមួយចំហៀងទៀតជាប្រាក់ ។ ហើយកាលណាវាយំ សូមឱ្យទឹកភ្នែកហូរចេញមកក្លាយទៅជាគជ់, ហើយនៅគ្រប់ពេលដែលវាញញឹម សូមឱ្យបបូរមាត់ក្រហមជាំនោះលេចចេញឡើងដូចជាផ្កាកូលាបកំពុងរីក ។

សេចក្តីប្រាថ្នានៃបងប្អូនស្រីបីនាក់នោះ, ជាពិសេសសេចក្តីប្រាថ្នារបស់នាងពៅ, បានធ្វើឱ្យព្រះបាទស៊ុលតង់ទ្រង់ចម្លែកក្នុងព្រះ



ទ័យណាស់ ហើយព្រះអង្គទ្រង់សម្រេចចព្រះទ័យថា និងបំពេញបំណងស្រីទាំងបីនេះឱ្យបាន ។ ប៉ុន្តែព្រះអង្គឥតទ្រង់មានព្រះបន្ទូលប្រាប់រឿងនោះឱ្យលោកនាយករដ្ឋមន្ត្រីដឹងទេ, ព្រះអង្គគ្រាន់តែផ្តាំឱ្យលោកនាយកឱ្យសម្គាល់ផ្ទះនោះឱ្យច្បាស់ ដើម្បីនឹងបង្គាប់ឱ្យគេមកនាំស្ត្រីទាំងនោះទៅថ្វាយព្រះអង្គនៅថ្ងៃស្អែក ។

ស្អែកឡើង លោកនាយករដ្ឋមន្ត្រីក៏ធ្វើតាមព្រះរាជបញ្ជាព្រះបាទស៊ុលតង់ ។ លោកបានបង្គាប់ឱ្យស្រីទាំងនោះស្លៀកពាក់យ៉ាងឆាប់ជាទីបំផុត ដើម្បីនឹងចូលទៅគាល់ព្រះអង្គ ។ លោកឥតបាននិយាយរឿងអ្វីប្រាប់ស្ត្រីទាំងនោះ ក្រៅពីថាព្រះករុណាត្រូវការចង់ជួបទេ ។ លោកនាយកក៏នាំកញ្ញាទាំងនោះ ចូលទៅថ្វាយបង្គំព្រះបាទស៊ុលតង់ក្នុងព្រះបរមរាជវាំង ។ ព្រះបាទស៊ុលតង់ក៏មានព្រះបន្ទូលសួរទៅនារីទាំងនោះថា : “នាងភ្លេចហើយឬនៅអំពីបំណងដែលនាងរាល់គ្នាបានប្រាថ្នាពីយប់ម្សិលមិញ? ចូរនាងនិយាយប្រាប់យើងមក, កុំលាក់នឹងយើងឱ្យសោះ ព្រោះយើងចង់ដឹង” ។

កាលបើបានឮព្រះរាជឱង្ការ ព្រះមហាក្សត្រដូច្នេះយុវតីទាំងបីដែលមិនសូវជាបានយកចិត្តទុកដាក់នឹងការដែលខ្លួនបាននិយាយគ្នាមកនោះប៉ុន្មាន, ក៏ទៅជាបែបភាន់ភាំងក្នុងគំនិត ។ នាងឱនមុខចុះនៅស្ងៀមទាំងអស់គ្នា ចំណែកនាងពៅដែលមានការប្រាថ្នាខ្ពស់ជាងគេ ក៏សម្តែងកិរិយាបែបប្លែកជាងគេបន្តិចដែរ ។ ព្រះបាទស៊ុលតង់ កាលបើ

ទ្រង់សង្កេតឃើញនារីទាំងអស់នៅស្ងៀម ព្រោះក្រែងនឹកអៀនខ្មាស នឹងព្រះអង្គ នឹងខ្លាចក្រែងព្រះអង្គទ្រង់អាក់អន់ព្រះទ័យ ក៏មានព្រះបន្ទូលបញ្ជាក់ថា : “សូមនាងកុំខ្លាចអ្វីឱ្យសោះ យើងមិនមែនហៅនាងមកដើម្បីធ្វើទុក្ខទោសអ្វីទេ ។ ប៉ុន្តែឥឡូវដោយយើងសម្គាល់ឃើញថា សំនួរដែលយើងសួរទៅនាងនោះ ទៅជាបានលទ្ធផលផ្ទុយនឹងបំណងយើងវិញ យើងក៏លែងត្រូវការសួរទៀតដែរ ព្រោះយើងដឹងបំណងនាងរៀងៗខ្លួនអស់ហើយ ។ ដូច្នេះនាងដែលប្រាថ្នាចង់បានយើងធ្វើជាស្វាមី នាងនឹងបានពេញចិត្តក្នុងថ្ងៃនោះពុំខាន ។ ចំណែកឯនាងពីរនាក់ឯណោះខ្ញុំនឹងរៀបចំការឱ្យជាមួយអ្នកធ្វើនំប៉័ងយើង នឹងជាមួយចៅ-ហ្វាយនៃនាយពិសេសរបស់យើងជាការចាំបាច់” ។

កាលបើព្រះបាទស៊ុលតង់ ទ្រង់សម្តែងឆន្ទៈព្រះអង្គដូច្នេះរួច, នាងពៅ, ដើម្បីជាគំរូដល់នាងបងៗ ក៏ស្ទុះទៅឱបព្រះបាទស៊ុលតង់សម្តែងអំណរគុណដល់ព្រះអង្គ ។ នាងពោលថា : “បពិត្រព្រះករុណាថ្លៃវិសេស ពិតមែនតែព្រះអង្គទ្រង់បានជ្រាប នូវសេចក្តីប្រាថ្នារបស់ខ្ញុំម្ចាស់, ប៉ុន្តែសេចក្តីប្រាថ្នានេះ គ្រាន់តែជាការជជែកគ្នាលែងសប្បាយប៉ុណ្ណោះទេ, ខ្ញុំម្ចាស់មិនសមនឹងទទួលកិត្តិយសដែលព្រះអង្គទ្រង់បានព្រះរាជទានដល់ខ្ញុំម្ចាស់នេះសោះ ហើយខ្ញុំម្ចាស់សូមព្រះករុណាទ្រង់ព្រះរាជទានអភ័យទោសដល់ខ្ញុំម្ចាស់ផង ចំពោះអំពើឥតអៀនខ្មាសរបស់ខ្ញុំម្ចាស់នេះ” ។ នាងបងពីរនាក់ទៀត ក៏បម្រុងសុំទោសព្រះរាជា



ដូច្នេះដែរ ប៉ុន្តែព្រះអង្គទ្រង់មានព្រះបន្ទូលកាត់ថា “ទេ, ទេ, កុំនាំវីវរអ្វីទៀត, សេចក្តីប្រាថ្នារបស់នាងម្នាក់ៗត្រូវតែបានសម្រេច” ។

ពិធីរៀបអាពាហ៍ពិពាហ៍ ក៏បានធ្វើឡើងដំណាលគ្នាក្នុងថ្ងៃនោះដូចដែលព្រះបាទស៊ុលតង់ទ្រង់មានព្រះបន្ទូលមែន ប៉ុន្តែមានការប្លែកគ្នាសម្បើមណាស់ ។ ការរៀបអាពាហ៍ពិពាហ៍នាងពៅប្រព្រឹត្តទៅដោយអធិកអធម ប្រកបដោយការសប្បាយគ្រប់បែបគ្រប់យ៉ាង សមជាពិធីរាជាភិសេកព្រះបាទស៊ុលតង់ នឹងព្រះនាងស៊ុលតានប្រទេសពែរ្សមែនៗ ។ ចំណែកឯមង្គលការនាងបងពីរនាក់វិញ ក៏បានធ្វើឡើងតាមរបៀបធម្មតា សមទៅតាមឋានៈអ្នកធ្វើនំប៉័ង នឹងចៅហ្វាយនៃនាយពិសេសរបស់ព្រះរាជា ។

ចាប់តាំងពីពេលនោះមក នាងបងទាំងពីរនាក់យល់ឃើញថាការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន មានសភាពអន់ថយជាងប្អូនស្រីឆ្ងាយណាស់។ ដូច្នេះ មិនបានត្រេកអរនឹងសុភមង្គលរបស់ខ្លួន ដែលបានសម្រេចទៅតាមតែបំណងរបស់ខ្លួនរៀងៗខ្លួន មានតែពីចង់លើសសេចក្តីប្រាថ្នានោះទៀតផង នាងបងពីរនាក់បែរទៅជាកើតសេចក្តីច្រណែនមហិមានឹងប្អូនស្រីខ្លួន លែងសប្បាយលែងរីករាយអ្វីទាំងអស់។ ប៉ុន្តែ នាងពុំទាន់មានពេលជួបនិយាយគ្នាផ្ទាល់អំពីការយល់ឃើញរៀងៗខ្លួន ចំពោះការដែលព្រះបាទស៊ុលតង់ទ្រង់សព្វព្រះទ័យប្អូនស្រីខ្លួនជាងខ្លួនទៅវិញ, នាងបានជួបគ្នាតែនៅពេលរៀបចំខ្លួន ដើម្បី

រៀបការតែប៉ុណ្ណោះ ។ ប៉ុន្តែពីរបីថ្ងៃក្រោយមក នៅពេលដែលនាងបានជួបគ្នានៅកន្លែងមុជទឹកសាធារណៈមួយដែលនាងបានសន្មតគ្នាពីពេលមុននោះ, នាងបងបង្អស់ ក៏និយាយទៅកាន់ប្អូនបន្ទាប់ថា : “ម្ដេចទៅអូន, តើអូនយល់ឃើញដូចម្ដេចអំពីប្អូនស្រីយើង? តើជាស្រីល្អសមធ្វើមហេសីស្ដេចទេ?”

- ទេបង, នាងបន្ទាប់ឆ្លើយ, ខ្ញុំដូចជាពុំយល់សោះហើយក្នុងរឿងនេះ ។ ខ្ញុំមើលពុំឃើញវាល្អត្រង់ណាសោះ ចុះហេតុអ្វីបានជាព្រះបាទស៊ុលតង់ទ្រង់ទតឃើញវាល្អ ហើយទ្រង់ស្រឡាញ់វាទៅវិញ ។ វានេះ ជាកូនក្មេងសោះ ហើយបងដឹងទេ តើបងឃើញវាយ៉ាងម៉េច ។ តើជាការត្រឹមត្រូវទេ ដែលព្រះបាទស៊ុលតង់មិនបានសម្លឹងមើលរូបបងឯងសិន, ព្រោះបងឯងមានទឹកមុខនៅក្មេងជាងអូន ហើយបងឯងនេះ សមនឹងឋានៈព្រះអង្គផង គួរណាស់តែព្រះអង្គរកយុត្តិធម៌ឱ្យបងឯង ក្នុងការដែលទ្រង់ទៅជាសព្វព្រះទ័យស្រឡាញ់វាទៅវិញនោះ ។

- ទេអូន, នាងបងចរចា, សូមកុំនិយាយពីបង បងឥតយល់ទាស់ទេ បើសិនជាព្រះបាទស៊ុលតង់ទ្រង់សព្វព្រះទ័យនឹងរូបអូន តែនេះព្រះអង្គទៅជាស្រឡាញ់មនុស្សក្រខ្វក់ទៅវិញ ជាហេតុគួរឱ្យបងកើតទុក្ខណាស់ ។ បងត្រូវតែសងសឹកវាឱ្យបាន ហើយអូនឯងក៏មានប្រយោជន៍ក្នុងរឿងនេះដូចបងដែរ ។ អាស្រ័យដោយហេតុនេះ, បងសូមឱ្យអូនពួតដៃជាមួយបង ដើម្បីនឹងបានគិតគូរគ្នាពីរឿងនេះ ដែល



មានប្រយោជន៍ស្មើគ្នានឹងដើម្បីជួយប្រាប់មធ្យោបាយណា ដែលប្អូនយល់ឃើញថាប្រសើរនោះ ប្រយោជន៍នឹងធ្វើបង្អាប់មុខវាឱ្យទាល់តែបាន ។

បន្ទាប់ពីការរួមគំនិតក្បត់ដ៏ចង្រៃនោះមក ស្រីបងប្អូនពីរនាក់ក៏បានជួបគ្នាជាញឹកញយ ហើយនៅគ្រប់ពេលវាជួបគ្នា វាគ្មានជំនុំរឿងអ្វីក្រៅពីរិះរកផ្លូវយ៉ាងណាដើម្បីបំផ្លាញសុភមង្គលព្រះនាងស៊ុលតានជាប្អូនបង្កើតនោះទេ ។ វាក៏បានរកឃើញមធ្យោបាយជាច្រើន ប៉ុន្តែដល់ជជែកគ្នាពីរឿងត្រូវប្រតិបត្តិការណ៍ទៅ ឃើញថាមានឧបសគ្គយ៉ាងសម្បើម លុះត្រាតែវាពុំហ៊ានប្រថុយយកមធ្យោបាយមួយណាមកអនុវត្តន៍ភ្លាមៗបាន ។ ដូច្នេះយូរៗម្ដង គេឃើញស្រីបងប្អូនពីរនាក់ទៅលេងប្អូនស្រីដោយលាក់ពុតអាក្រក់គួរផ្ដន្ទាទោស ហើយនៅពេលដែលវាទៅលេងប្អូននោះ វាធ្វើជាសម្ដែងសេចក្ដីរីករាយរាក់ទាក់ទៅរកប្អូនជាក្រៃលែងប្រយោជន៍ឱ្យប្អូនជឿថា វាជាបងទាំងពីរមានសេចក្ដីសោមនស្សជាពន់ពេកណាស់ ដែលបានឃើញប្អូនស្រីបានឡើងឋានៈខ្ពង់ខ្ពស់យ៉ាងនេះ ។ ចំណែកឯព្រះនាងស៊ុលតានជាប្អូនវិញ, នាងបានទទួលបងទាំងពីរដោយភារកិច្ចធម្មតា ដែលប្អូនត្រូវតែមានដល់បង ព្រោះនាងជាស្ត្រីមិនចេះឆ្នើងកន្ទ្រើង ដោយអាងយសសក្ដិ ហើយនាងនៅតែស្រឡាញ់បង ដោយភាពជិតស្និទ្ធដូចជាពីពេលមុនដដែល ។

ពីរបីខែបន្ទាប់ពីពេលរៀបអាពាហ៍ពិពាហ៍មក, ព្រះនាង

ស៊ុលតានក៏ទ្រង់មានគភ៌ ។ ព្រះបាទស៊ុលតង់ក៏ទ្រង់មានព្រះទ័យត្រេកអរជាពន់ពេក ។ ហើយដំណឹងដ៏រីករាយនេះ បន្ទាប់ពីបានលាន់ឮពាសពេញនៅក្នុងព្រះបរមរាជវាំង ក៏បានផ្សាយចេញលាន់ឮរហូតទៅដល់ក្នុងសង្កាត់នានា នៃរាជធានីប្រទេសពែរ្ស៍ ។ ស្រីជាបងទាំងពីរនាក់កាលបើបានឮដំណឹងនេះ ក៏បានចូលទៅសម្ដែងសេចក្ដីរីករាយដល់ប្អូនដែរ ។ ហើយនៅពេលនោះ, ស្រីទាំងពីរក៏បាននិយាយរំលឹកព្រះនាងស៊ុលតានអំពីការរកឆ្មប ដែលព្រះនាងមុខជានឹងត្រូវការ ដើម្បីនឹងជួយប្រសូតបុត្រនាង ហើយស្រីទាំងពីរនោះក៏បានអង្វរព្រះនាងថាសូមកុំឱ្យយកឆ្មបឯណាក្រៅពីនាងជាបងពីរនាក់នោះ ។

ព្រះនាងស៊ុលតាន ក៏មានបន្ទូលតបទៅវិញដោយសេចក្ដីគួរសមទៅថា : "អ្នកបងទាំងពីរ, បើសិនជាការជ្រើសរើសនេះ អាចសម្រេចចេញពីខ្លួនខ្ញុំផ្ទាល់បាននោះ ខ្ញុំគ្មានត្រូវការយកនរណាដទៃទៀតទេ ដូចអ្នកបងបានជ្រាបនូវចិត្តខ្ញុំស្រាប់ហើយ។ ខ្ញុំសូមអរគុណនឹងឆន្ទៈល្អនេះ ។ ប៉ុន្តែខ្ញុំពុំអាចសម្រេចការអ្វីផ្សេងៗជួសព្រះបាទស៊ុលតង់បានឡើយ ។ ហេតុនេះ សូមអ្នកបងជម្រាបប្ដីអ្នកបងឱ្យគាត់ពឹងពាក់រកសម្លាញ់គាត់ ដើម្បីចូលសុំសេចក្ដីអនុគ្រោះនេះពីព្រះបាទស៊ុលតង់ទៅ ហើយបើសិនជាព្រះអង្គទ្រង់សួរយោបល់ខ្ញុំពីរឿងនោះៗ សូមអ្នកបងជឿចុះថា, ខ្ញុំមិនត្រឹមតែអរគុណព្រះអង្គដែលទ្រង់សព្វព្រះរាជហឫទ័យសួររឿងនេះដល់ខ្ញុំផងទេ គឺខ្ញុំថែមទាំងអរគុណព្រះ



អង្គជាច្រើនទៀត បើសិនជាព្រះអង្គព្រមរើសយកអ្នកបងធ្វើជាឆ្មបខ្ញុំនោះ" ។

ស្វាមីស្រីពីរនាក់ក៏ទទូចសុំពឹងពាក់ជននៅក្នុងព្រះបរមរាជវាំងដែលជាអ្នកឧបត្ថម្ភខ្លួន ព្រមទាំងសូមអង្វរឱ្យគេជួយក្រាបទូលព្រះបាទស៊ុលតង់ សុំឱ្យព្រះអង្គរើសយកភរិយាខ្លួនធ្វើជាឆ្មបព្រះនាងក្នុងការប្រសូតបុត្រ ។ ឧបត្ថម្ភកជន ក៏បានខំជួយខ្នះខ្នែងក្នុងរឿងនេះយ៉ាងពេញទំហឹង លុះត្រាតែព្រះបាទស៊ុលតង់ ទ្រង់ព្រមទទួលយករឿងនោះទៅពិនិត្យ ។ នៅពេលមួយព្រះអង្គក៏ទ្រង់មានព្រះបន្ទូលនិយាយជាមួយនឹងព្រះនាងស៊ុលតានថា ព្រះអង្គយល់ថាព្រះជេដ្ឋភគិនីថ្លៃ[១] សមយកធ្វើជាឆ្មបសម្រាប់ជួយប្រសូតបុត្រម្ចាស់អូនប្រសើរជាងឆ្មបដទៃទៀត ប៉ុន្តែព្រះអង្គពុំទាន់ហ៊ានតែងតាំងភ្លាម ព្រោះពុំទាន់បានទទួលសេចក្ដីយល់ព្រមពីព្រះនាងជាមុនផង ។ ព្រះនាងស៊ុលតានរំភើបញាប់ញ័រនឹងសេចក្ដីគោរព ដែលព្រះបាទស៊ុលតង់ទ្រង់មានមកលើខ្លួនដូច្នេះ ក៏មានព្រះសវនីយតបថា: "បពិត្រព្រះករុណាថ្លៃវិសេសខ្ញុំម្ចាស់បានបម្រុងខ្លួនស្រេចជាមុនថានឹងធ្វើការអ្វីៗតាមតែព្រះរាជបញ្ជារបស់ព្រះអង្គ ។ ដូច្នេះដោយព្រះអង្គទ្រង់មានព្រះទ័យមេត្តាសណ្ដោសនឹងរើសយកបងស្រីខ្ញុំម្ចាស់នោះៗ ខ្ញុំម្ចាស់សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជាអនេកចំពោះព្រះអង្គ ព្រោះកាយវិការនេះបណ្ដាល

(១) បងថ្លៃស្រី

មកតែពីសេចក្ដីស្នេហារបស់ព្រះអង្គមកលើរូបខ្ញុំម្ចាស់តែប៉ុណ្ណោះ ។ ហើយខ្ញុំម្ចាស់សូមទូលព្រះអង្គដោយត្រង់ថា ខ្ញុំម្ចាស់មានសេចក្ដីរីករាយជាក្រៃលែងនឹងទទួលបងខ្ញុំម្ចាស់ជាជាងអ្នកដទៃទៀត» ។

ព្រះបាទស៊ុលតង់ក្ដូរសាក៏តែងតាំងបងស្រីព្រះនាងស៊ុលតានពីរនាក់ឱ្យធ្វើជាឆ្មបព្រះនាង ។ ហើយចាប់តាំងពីពេលនោះមក ស្រីទាំងពីរក៏បានចូលនៅក្នុងព្រះបរមរាជវាំងយ៉ាងសប្បាយ ដោយវារកឃើញឱកាសល្អត្រូវតាមបំណងខ្លួន ដើម្បីប្រព្រឹត្តអំពើកំណាចគួរឱ្យខ្ពើម ប្រឆាំងនឹងព្រះនាងស៊ុលតានជាប្អូន ។

ពេលប្រសូតបុត្រក៏បានមកដល់ ហើយនាងស៊ុលតានក៏បានប្រសូតព្រះអង្គម្ចាស់មួយមកល្អដូចជាពន្លឺថ្ងៃ ។ ប៉ុន្តែលម្អនឹងភាពទន់ខ្សោយនេះពុំអាចញ៉ាំងចិត្តស្រីឥតមេត្តានោះ ឱ្យទោទន់អាណិតព្រះរាជកុមារបន្តិចសោះឡើយ ។ វាបានយកក្រណាត់សំពត់រុំកូនឆ្កែតនោះធ្វើបែបលេងៗ រួចយកទៅដាក់ក្នុងកញ្ច្រែងមួយ បណ្ដែតឱ្យរសាត់ទៅតាមប្រឡាយទឹក ដែលហូរកាត់តាមក្បែរដំណាក់ព្រះនាងស៊ុលតាន ទើបវាយកកូនឆ្កែតូចមួយមកដាក់នៅកន្លែងនោះ ហើយដើរនិយាយផ្សាយថា ព្រះនាងស៊ុលតានបានប្រសូតបុត្រមកជាសត្វឆ្កែ ។ ដំណឹងដ៏អពមង្គលនេះបានឮទៅដល់ព្រះបាទស៊ុលតង់ ហើយព្រះបាទស៊ុលតង់ក៏ទ្រង់តូចព្រះទ័យជាក្រៃលែងស្ទើរតែនឹងបណ្ដាលឱ្យមានលទ្ធផលដ៏អាក្រក់ដល់ព្រះនាងមហេសី បើកុំតែបានលោកនាយករដ្ឋមន្ត្រីពោល



បំភ្លឺព្រះអង្គថា ព្រះអង្គពុំអាចចាត់ភាពចម្លែកដែលកើតមកពីធម្មជាតិនេះឱ្យព្រះនាងទទួលខុសត្រូវទេ ។

កញ្ច្រែងដែលគេបានដាក់ព្រះរាជកុមារបណ្ដែតចោលនោះ បានរសាត់ទៅតាមប្រឡាយទឹក រហូតទៅដល់ខាងក្រៅកំពែងជញ្ជាំងដែលខណ្ឌដំណាក់ព្រះនាង ហើយចាប់តាំងពីទីនោះទៅ, កញ្ច្រែងក៏រសាត់កាត់តាមទីសួននានានៃប្រាសាទ ។ ដោយទេសកាលនាយតម្រួតសួនច្បារព្រះបាទស៊ុលតង់ ដែលជាមន្ត្រីមានបណ្ដាសក្ដិម្នាក់ ហើយដែលត្រូវគេស្រឡាញ់រាប់អានជាច្រើនបំផុត នៅក្នុងព្រះនគរ បានអញ្ជើញដើរលេងក្នុងសួនបណ្ដោយតាមប្រឡាយទឹក ក៏បានប្រទះឃើញកញ្ច្រែងអណ្ដែត ។ លោកក៏ស្រែកហៅអ្នកថែសួនច្បារ ហើយចង្អុលប្រាប់ទៅអ្នកនោះថា “ចូរឯងទៅឱ្យលឿន ហើយរើសយកកញ្ច្រែងនោះមកឱ្យខ្ញុំ ដើម្បីខ្ញុំពិនិត្យមើលតើមានវត្ថុអ្វីនៅក្នុងនោះ” ។ អ្នកថែសួនក៏ចេញទៅមួយរំពេច លុះទៅដល់គាត់ក៏ឈោងពីមាត់ប្រឡាយយកចបជីកថ្កក់ទាញកញ្ច្រែងនោះលើកឡើង ហើយយកទៅជូនចៅហ្វាយគាត់ ។

នាយតម្រួតសួនមានសេចក្ដីភ្ញាក់ផ្អើលជាខ្លាំង កាលបើឃើញកូនឆ្កែតមួយរុំក្រណាត់ដាក់ក្នុងកញ្ច្រែងនោះ ហើយកូនឆ្កែតនោះ ពិតមែនតែនៅរស់ហើយគួរឱ្យចង់មើល ប៉ុន្តែលោកមើលទៅហាក់ដូចជាពុំសូវឃើញល្អប៉ុន្មាន ។ ជាឱកាសល្អ, នាយតម្រួតសួននោះមានប្រពន្ធជាយូរពេលក្រៃលណាស់មកហើយ ប៉ុន្តែទេវតាពុំទាន់បានដាក់ទាន

បុត្រមួយដល់លោកសោះ ។ ដូច្នេះ លោកក៏ឈប់ដើរលេង ហើយបង្គាប់ឱ្យអ្នកថែសួនកាន់កញ្ច្រែងនោះដើរមកតាមលោក ។ លុះលោកត្រឡប់មកដល់សណ្ឋាគារលោកវិញ ដែលមានផ្លូវចូលតាមសួនព្រះរាជវាំង លោកក៏ចូលទៅក្នុងបន្ទប់ប្រពន្ធលោកភ្លាម ហើយនិយាយថា "ឯងហើយ យើងពុំទាន់មានកូនមួយសោះ ឥឡូវទេវតាលោកបានដាក់ទានកូនឱ្យយើងមួយហើយ ។ ហេតុនេះចូរឯងរកមេដោះមួយឱ្យបានឆាប់មក ហើយចូរឯងមើលថែរក្សាកូននេះដូចជាកូនយើងបង្កើត ។ ខ្ញុំទទួលស្គាល់ថាជាកូនតាំងពីពេលនេះទៅ" ។ ប្រពន្ធក៏ទទួលយកកូនង៉ែតនោះដោយរីករាយ សម្តែងអាការៈឱ្យឃើញថា នាងចង់បានកូនមែន ។ នាយតម្រួតសួនមិនចង់និយាយរឿងនេះឱ្យវែងឆ្ងាយប្រាប់ប្រពន្ធទៀតទេ តែគាត់បាននឹកក្នុងចិត្តថា : "អញយល់ច្បាស់ថា កូននេះលេចចេញមកពីខាងទិសដំណាក់ព្រះនាងស៊ុលតាន ប៉ុន្តែការនេះមិនត្រូវមុខងារអញដើម្បីនឹងទៅពិនិត្យការអ្វីៗនៅកន្លែងនោះទេ ឬក៏ទៅបណ្តាលឱ្យមានចលាចលនៅក្នុងកន្លែង ដែលសេចក្តីស្ងប់ស្ងៀមត្រូវតែមានជាការចាំបាច់ឡើយ" ។

ឆ្នាំជាបន្ទាប់មក, ព្រះនាងស៊ុលតានក៏ប្រសូតព្រះរាជបុត្រមួយព្រះអង្គទៀត, ស្រីឆ្មបទាំងពីរក៏គ្មានចិត្តករុណាអ្វីបន្តិចដល់ព្រះអង្គម្ចាស់ខាងក្រោយនេះដែរ ។ វាបានយកកូនង៉ែតនោះដាក់កញ្ច្រែងបណ្តែតតាមប្រឡាយទឹកដូចជាលើកមុន រួចវាក៏ពោលភ្លែងថា ព្រះ



នាងស៊ុលតានប្រសូតបុត្រមកជាសត្វឆ្មា ។ ជាសំណាងល្អរបស់កូនង៉ែតនោះ, នាយតម្រួតសួនបាននៅក្បែរប្រឡាយទឹកនោះទៀត, លោកក៏រើសយកកញ្ច្រែងឡើងពីទឹក រួចយកទៅឱ្យភរិយាលោក ដោយផ្តាំនឹងភរិយាថា សុំឱ្យមើលបីបាច់ថែរក្សាកូនខ្ចីនោះដូចជាកុមារមុនផង ។ នាងភរិយាក៏បានយកចិត្តទុកដាក់ចិញ្ចឹមបីបមកូនង៉ែតអភព្វ ដោយក្តីស្នេហាជាទីបំផុត ម្យ៉ាងបណ្តាលមកពីចិត្តរបស់គាត់ផ្ទាល់ ម្យ៉ាងដើម្បីឱ្យត្រូវតាមបណ្តាំស្វាមី ។

ព្រះបាទស៊ុលតង់ប្រទេសពែរ្ស៍ កាលបើទ្រង់ជ្រាបនូវដំណឹងខាងក្រោយនេះ, ក៏ទ្រង់អាក់អន់ព្រះទ័យលើសពីលើកមុនទៅទៀត ។ ព្រះអង្គទ្រង់សម្តែងអាការៈក្រោធទៅហើយ បើសិនជាការព្រមានរបស់លោកនាយករដ្ឋមន្ត្រីមិនបានជួយញាំងព្រះទ័យព្រះអង្គឱ្យស្ងាត់ស្ងៀមទៅវិញទេ ។

ទីបំផុត, នៅឆ្នាំទីបីព្រះនាងស៊ុលតាន ទ្រង់ប្រសូតព្រះរាជបុត្រមួយទៀត តែម្តងនេះជាក្សត្រី ។ ព្រះរាជកុមារីខាងក្រោយនេះក៏ទទួលវាសនាដូចជាព្រះរៀមមុនៗដែរ ។ ស្រីបងប្អូនពីរនាក់ ដែលបានកំណត់ក្នុងចិត្តជាស្រេចហើយថា នឹងឈប់ប្រព្រឹត្តអំពើអាក្រក់គួរឱ្យខ្ពើមនេះ លុះត្រាតែវាបានឃើញព្រះនាងស៊ុលតានប្អូនស្រីវាយ៉ាងហោចណាស់ក៏ខ្ចាត់ចេញពីព្រះបរមរាជវាំង, អាម៉ាសមុខរកអ្វីប្រៀបគ្មានដែរ, ក៏នៅតែប្រព្រឹត្តអំពើលាមកទៅលើកូនង៉ែតព្រះរាជាដដែល

ដោយដាក់បណ្តែតចោលតាមប្រឡាយទឹក ។ តែជាកុសលផលបុណ្យ លោកជួយព្រះអង្គម្ចាស់ក្សត្រី ក៏ត្រូវបានលោកនាយតម្រួតស្ទួនដដែល ជួយស្រោចស្រង់ជីវិតផុតពីក្តីមរណៈទៀត ហើយបានទទួលការចិញ្ចឹម បីបាច់ពីលោក ដូចជាព្រះរៀមពីរនាក់មុនដែរ ។

បន្ទាប់ពីអំពើមនុស្សធម៌នេះមក, ស្រីពីរនាក់ក៏បានប្រើមធ្យោបាយកុហកនឹងបោកប្រាសដូចជាលើកមុនទៀត ។ វាបានបង្ហាញឈើមួយដុំឱ្យគេឯងឃើញ ហើយនិយាយបង្កាច់ថា ព្រះនាងស៊ុលតានបានប្រសូតបុត្រមកជាដុំឈើ ហើយគឺជាឈើថ្នឹម ដែលគេសង់នៅមាត់ផ្លូវចូលផែកប៉ាល់សម្រាប់ការពារនឹងខ្យល់រលក ។

ម្តងនេះ កាលបើព្រះបាទស៊ុលតង់ទ្រង់បានជ្រាបនូវដំណឹងចម្លែកខាងក្រោយបំផុតនេះ ព្រះអង្គពុំអាចទប់ពុំក្រោធបានទៀតឡើយ ។ ទើបព្រះអង្គមានព្រះបន្ទូលសូរសីហនាទថា: “យីម៉េច, មិនស្រីចង្រៃមិនសមឋានៈអញនេះ បើសិនជាអញទុកឱ្យវារស់នៅក្នុងទីនេះ តទៅទៀត វាមុខជានឹងបង្កើតរបស់អាក្រក់ៗដាក់ពេញប្រាសាទអញទៅហើយឬ? ទេ, ការនេះមិនត្រូវឱ្យកើតមានបានទេ, វានេះជាស្រីចង្រៃអញត្រូវតែលាងគំរង់នេះ ឱ្យស្អាតចេញពីលោកនេះ” ។ ដូច្នេះ ព្រះអង្គក៏ទ្រង់ប្រកាសកាត់ទោសប្រហារជីវិត រួចក៏ទ្រង់បង្គាប់ទៅលោកនាយករដ្ឋមន្ត្រីឱ្យចាត់ការនេះឱ្យបានសម្រេច ។

លោកនាយករដ្ឋមន្ត្រីនិងជននៅក្នុងព្រះបរមរាជវាំង ដែលនៅ

ជួបជុំគ្នាក្នុងទីនោះ ក៏ឱនលុតជង្គង់សូមអង្វរព្រះអង្គដើម្បីសុំលប់ចោលសេចក្ដីសម្រេចព្រះទ័យនោះ។ លោកនាយករដ្ឋមន្ត្រីក៏មានប្រសាសន៍ឡើងថា : “បពិត្រព្រះករុណាថ្លៃវិសេស. សូមព្រះតេជៈតំកល់លើត្បូង សូមល្អងធូលីប្រោសព្រះរាជទានអនុញ្ញាត ឱ្យទូលព្រះបង្គំនិយាយទូលព្រះអង្គបន្តិចថា ច្បាប់សម្រាប់ផ្ដន្ទាទោសប្រហារជីវិតបានចែងឡើង ដើម្បីដាក់ទណ្ឌកម្មតែដល់ជនណាដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋ រីឯការប្រសូតបុត្រនៃព្រះនាងស៊ុលតាន ពិតមែនជាការចម្លែកពុំដែលឃើញ ពុំដែលឮ ក៏ប៉ុន្តែមិនមែនជាអំពើឧក្រិដ្ឋទេ ។ តើអាងអ្វីដែលថា ឱ្យព្រះនាងត្រូវទទួលទោសក្នុងរឿងនេះ? មានស្រីឯទៀតជាច្រើនដែរដែលបានកើតបុត្រចម្លែកៗ ដូច្នេះហើយនឹងនៅតែមានដូច្នេះជារៀងរាល់ថ្ងៃទៀតផង ។ ស្ត្រីទាំងនោះត្រូវទទួលសេចក្ដីឈឺចាប់ក្នុងចិត្តមែន ប៉ុន្តែស្រីទាំងនោះឥតដែលត្រូវមានទោសទេ ។ ព្រះករុណាថ្លៃវិសេសអាចបណ្ដេញវាចេញឱ្យបាត់ពីព្រះភក្ត្រ ប៉ុន្តែត្រូវទុកជីវិតវា។ សេចក្ដីទុក្ខព្រួយដែលវានឹងត្រូវទទួល លុះត្រាអស់មួយជីវិតវានោះ ដោយសារវាត្រូវបាត់បង់នូវសេចក្ដីទទួលរាប់អានពីព្រះអង្គជាទារុណកម្មមួយដ៏សម្បើមណាស់ទៅហើយ” ។ ព្រះបាទស៊ុលតង់ប្រទេសពៃរ្យ៍ក៏ទ្រង់នៅស្ងៀម ។ ហើយដោយហេតុថាព្រះអង្គទ្រង់យល់នូវការអយុត្តិធម៌ ដែលព្រះអង្គទ្រង់បានប្រកាសផ្ដន្ទាទោសប្រហារជីវិតព្រះនាងស៊ុលតានមកពីការប្រសូតបុត្រខុសគេ



នោះ ហើយទោះបីការនេះមិនមែនដូច្នោះក៏ដោយ ក៏ព្រះអង្គមិនត្រូវធ្វើយ៉ាងនេះដែរ ទើបព្រះអង្គមានព្រះបន្ទូលថា: “បើដូច្នេះត្រូវទុកវាឱ្យរស់នៅចុះ ប៉ុន្តែត្រូវផ្ដន្ទាទោសវាជារាល់ថ្ងៃកុំខាន ។ ហេតុនេះត្រូវឱ្យគេសង់រានមួយនៅមាត់ផ្លូវចូលទៅក្នុងវិហារអ៊ីស្លាម ដែលធំជាងគេ ត្រូវមានបង្អួចមួយបើកចំហជានិច្ច រួចត្រូវយកមីស្រីចង្រៃនេះទៅឱ្យនៅក្នុងនោះ ឱ្យសំពត់អាវវាស្លៀកពាក់យ៉ាងក្រខ្វក់បំផុត ដើម្បីឱ្យពួកអ៊ីស្លាមម្នាក់ៗ ដែលត្រូវចូលទៅព្រះវិហារស្ដោះទឹកមាត់ដាក់មុខវា នៅពេលដើរចូលទៅសូត្រធម៌ ។ ហើយបើសិនជាមាននរណាធ្វើល្មើសនឹងបញ្ញត្តិនេះ ខ្ញុំនឹងផ្ដន្ទាទោសដូចស្រីទុរយសនេះដែរ ។ ដូច្នេះដើម្បីឱ្យការនេះត្រូវបានគេគោរព. ខ្ញុំសូមឱ្យលោកនាយកចាត់ការឱ្យមានមនុស្សចាំឃ្លាំមើលផង” ។

ព្រះសូរសៀង ដែលព្រះបាទស៊ុលតង់ទ្រង់ប្រកាសដាក់កំហិតដល់ព្រះនាងស៊ុលតាននេះ បានបិទមាត់លោកនាយករដ្ឋមន្ត្រីឱ្យនៅស្ងៀមឈឹង ។ លោកនាយកក៏រៀបចំចាត់ចែងការនេះ ជាហេតុឱ្យស្រីប្រច័ណ្ឌពីរនាក់ជាបងសប្បាយចិត្តជាក្រៃលែង។ រានសម្រាប់ដេកក៏បានសង់រួចជាស្រេច ហើយនាងស៊ុលតានដែលមានសន្ដានគួរឱ្យសន្ដោសនោះ. ក៏ត្រូវគេនាំយកទៅដាក់នៅកន្លែងនោះ បន្ទាប់ពីពេលព្រះនាងយាងចេញពីកន្លែងប្រសូតបុត្រ តាមព្រះរាជបញ្ជាព្រះបាទស៊ុលតង់។ ហើយចាប់តាំងពីពេលនោះមក ព្រះនាងក៏ត្រូវទទួលអំពើដ៏ថោកទាប

មានការចំអកឡកឡឺយនិងការមើលងាយគ្រប់បែបគ្រប់យ៉ាងពីប្រជាជន គឺជាអំពើមួយដែលព្រះនាងពុំត្រូវទទួលរងសោះ ប៉ុន្តែនាងស៊ូខាំមាត់នៅស្ងៀមទ្រាំទទួលទោសនោះ ជាហេតុញ៉ាំងទឹកចិត្តជនដែលចេះរើកញែករកការខុសត្រូវម៉ត់ចត់ជាងជនសាមញ្ញឱ្យមានការស្ងើចសរសើរនិងអាណិតព្រះនាងជាច្រើន ។

សូមដំណាលពីព្រះអង្គម្ចាស់ពីរព្រះអង្គ និងព្រះអង្គម្ចាស់ក្សត្រីជាព្រះរាជបុត្រព្រះនាងម្តងវិញ. ព្រះអង្គទ្រង់បានទទួលការចិញ្ចឹមបីបាច់ពីសំណាក់លោកនាយតម្រួតស្ទួន និងភរិយាលោកដោយសេចក្តីស្នេហាថ្នាក់ថ្នមវិស័យដូចមាតាបិតាព្រះអង្គបង្កើត ហើយសេចក្តីស្នេហានេះកាន់តែកើតមានធំឡើងៗជាលំដាប់ណា ដែលព្រះអង្គម្ចាស់ទាំងឡាយមានវ័យធំបន្តិចឡើងៗ និងតាមសញ្ញានៃឫកពាអានុភាពដែលលេចចេញឡើង ។ តាមការចំណាំនេះ គេសម្គាល់ឃើញថា ព្រះអង្គម្ចាស់ក្សត្រីទ្រង់បែបមានបញ្ញាវៀងវៃជាងព្រះរៀមទាំងពីរ ។ ក្រៅពីនេះ មាតាបិតាចិញ្ចឹមទ្រង់ស្រឡាញ់ព្រះអង្គម្ចាស់ក្សត្រីច្រើនជាងព្រះអង្គម្ចាស់បន្តិច ដោយមកពីព្រះអង្គម្ចាស់ក្សត្រីកាន់តែមានព្រះរូបល្អឡើងជារាល់ថ្ងៃ និងដោយព្រះនាងមានភាពទន់ភ្លន់និងចរិយាថ្លៃថ្នូរខុសពីក្មេងធម្មតា ព្រមទាំងមានទឹកព្រះភក្ត្រអាចប្រដូចបានតែទៅនឹងបុត្រនៃខត្តិយវង្សទាំងឡាយ ។ ដើម្បីសម្គាល់ព្រះអង្គម្ចាស់ទាំងពីរនោះតាមលំដាប់ថ្ងៃខែប្រសូតមក លោកនាយស្ទួននិងភរិយាបានដាក់



ព្រះនាមព្រះអង្គម្ចាស់បងថា បាម៉ាន. ព្រះអង្គម្ចាស់ប្អូន ប៉ៃរិស (គឺជាព្រះនាមអតីតមហាក្សត្រប្រទេសពៃរ៉្ស) ។ ឯព្រះនាងក្សត្រីវិញ. គាត់បានថ្វាយព្រះនាមថាប៉ារីសាដ ដែលជាព្រះនាមដែលគេបានដាក់ថ្វាយព្រះមហេសី ឬព្រះអង្គម្ចាស់ក្សត្រីក្នុងប្រទេសជាច្រើនមកហើយ ។

កាលបើព្រះអង្គម្ចាស់ទាំងពីរមានព្រះវ័យចម្រើនធំល្មមហើយ. នាយតម្រួតស្ទួនក៏បានរកគ្រូម្នាក់ឱ្យមកបង្រៀនព្រះរាជកុមារឱ្យរៀនមើលរៀនសរសេរ ។ ចំណែកឯព្រះរាជកុមារី ដែលព្រះអង្គចេះតែទៅអង្គុយស្តាប់គេរៀន ក៏កើតព្រះទ័យចង់រៀនមើលរៀនសរសេរនឹងគេដែរ ពិតមែនតែនៅក្មេងជាងព្រះកុមារទាំងពីរ ។ នាយតម្រួតស្ទួនសប្បាយចិត្តនឹងចេតនាល្អនោះ ក៏សុំគ្រូនោះឱ្យព្រះនាងចូលរៀនជាមួយនឹងព្រះអង្គម្ចាស់ផង ។ មិនយូរប៉ុន្មានអាស្រ័យដោយព្រះនាងមានបញ្ញាវៀងវៃនិងមានចិត្តប្រណាំងប្រជែង. ព្រះនាងក៏មានការចេះចាំច្រើនជាងព្រះអង្គម្ចាស់ព្រះរៀម ។

ចាប់តាំងពីពេលនោះមក. ព្រះអង្គម្ចាស់ទាំងបីព្រះអង្គទ្រង់រៀនមុខវិជ្ជាខាងវិចិត្រសិល្ប៍ផ្សេងៗ នឹងគ្រូតែមួយជាមួយគ្នា ដូចជាភូមិសាស្ត្រ. កវីនិពន្ធន៍. ពង្សាវតារ និងវិទ្យាសាស្ត្រផ្សេងៗ ទោះវិទ្យាសាស្ត្រអាថិកំបាំងក៏ដោយ ។ ហើយដោយហេតុតែព្រះអង្គម្ចាស់ទាំងឡាយទ្រង់សិក្សាមុខវិជ្ជាទាំងនោះ ហាក់ដូចជាគ្មានឃើញលំបាកត្រង់កន្លែងណាសោះ ព្រះអង្គក៏ទ្រង់សិក្សារឆាប់ចេះចម្រើនជាទីបំផុត

លុះត្រាតែគ្រូទាំងឡាយមានសេចក្តីងឿងឆ្ងល់ ហើយមិនយូរប៉ុន្មានគ្រូទាំងអស់ក៏លាន់មាត់ពោលបញ្ជាក់ដោយត្រង់ថា ព្រះអង្គម្ចាស់ទាំងឡាយទ្រង់បានសិក្សាមុខវិជ្ជាទាំងអស់ ចេះសព្វគ្រប់ជ្រៅជ្រះជាងលោកទៅទៀត ដូច្នេះលោកគ្មានអ្វីនឹងបង្រៀនព្រះអង្គម្ចាស់ទាំងបីព្រះអង្គនេះទៀតទេ ទោះតិចតួចក៏ដោយ ។ នៅពេលវិស្សមោកាល. ព្រះអង្គម្ចាស់ក្សត្រីទ្រង់រៀនវិជ្ជាភ្លេង. រៀនច្រៀងនិងរៀនលេងភ្លេងជាច្រើនមុខទៀត ។ កាលបើព្រះអង្គម្ចាស់ព្រះរៀមទៅរៀនជិះសេះ. ព្រះនាងក៏ទៅរៀនជិះសេះជាមួយដែរ លុះត្រាតែចេះគង់សេះ. ចេះបាញ់ធ្នូ ចោលដំបងចោលលំពែងយ៉ាងប៉ិនប្រសប់ដូចជាព្រះរៀមដែរ ព្រោះព្រះនាងមិនចង់ឱ្យព្រះរៀមចេះមុខវិជ្ជាអ្វីលើសព្រះនាងឡើយ ។ ហើយព្រះនាងទ្រង់តែងចេះវិជ្ជានីមួយៗថ្មីកជាងព្រះរៀមផង ។

នាយតម្រួតសួន ដែលមានទឹកចិត្តសប្បាយជាពន់ពេក ដោយបានឃើញកូនចិញ្ចឹមរបស់ខ្លួនមានការចម្រើនសព្វគ្រប់ទាំងអស់ ទាំងខាងរាងកាយក៏ដូចជាខាងចំណេះវិជ្ជាសមទៅនឹងការចំណាយដ៏ច្រើនដែលគាត់ធ្វើមក ដើម្បីអប់រំកូនគាត់ទាំងបី ។ ការចម្រើននេះបានកើនហួសពីការសង្ឃឹមរបស់គាត់ទៅទៀត ។ ដូច្នេះ គាត់ក៏ធ្វើការចំណាយម្តងទៀត ដើម្បីសេចក្តីស្នេហាដល់បុត្រចិញ្ចឹមនោះ ។ តាំងពីដើមមករហូតមកទល់នឹងពេលនេះ. នាយតម្រួតសួនតែងពេញចិត្តនឹងផ្ទះចាស់គាត់ ដែលតាំងនៅក្នុងកំពែងព្រះបរមរាជវាំងនេះណាស់



គាត់គ្មានសង់ផ្ទះនៅឯជនបទទៀតទេ ។ ប៉ុន្តែឥឡូវនេះ គាត់ទើបតែនឹងបានទិញផ្ទះមួយឆ្ងាយពីទីក្រុងបន្តិច ដោយមានទាំងដីទំនេរអាចភ្ជួរដាំដំណាំបានយ៉ាងធំផង. កន្លែងខ្លះជាវាលស្មៅ. កន្លែងខ្លះជាព្រៃឈើ ។ ហើយដោយហេតុតែគាត់យល់ថា គេហស្ថាននោះមិនសូវល្អ. មិនសូវស្រួលនៅ គាត់ក៏សម្រុតចុះមកនៅទាបវិញ ។ ហើយគាត់ឥតសំចៃធនធាន ដើម្បីនឹងតុបតែងទីជុំវិញផ្ទះនោះឱ្យបានល្អឡើយ ។ គាត់តែងទៅកាន់ទីផ្ទះថ្មីនោះជារាល់ថ្ងៃ ដើម្បីតឿនកម្មករជាច្រើនដែលគាត់បានជួលមកនោះឱ្យខំធ្វើការឱ្យបានហើយឆាប់ ។ លុះគាត់ធ្វើបានបន្ទប់មួយសមល្មមនឹងគាត់ទៅនៅបាន គាត់បានទៅសម្រាកលេងនៅទីនោះអស់ពេលជាច្រើនថ្ងៃ នៅពេលដែលគាត់គ្មានកិច្ចការអ្វីនឹងបំពេញនៅឯទីសួន ។ ដោយសេចក្តីសង្វាតឧិហាតរបស់គាត់ មិនយូរប៉ុន្មានក៏បានធ្វើផ្ទះនោះហើយ ហើយនៅពេលដែលគេរៀបចំផ្ទះលម្អដោយគ្រឿងតុទូ ដើម្បីឱ្យសមនឹងផ្ទះថ្មី ។ គាត់បានទៅបង្គាប់ឱ្យគេកាប់ជម្រះសម្អាតទីសួនតាមគំនូរ ដែលគាត់បានត្រាយទុកជាស្រេចតាមរបៀបធម្មតាដែលគេ ធ្លាប់បានឃើញមកនៅប្រទេសពែរ្សបណ្តាផ្ទះពួកគហបតីធំៗ ។ ក្រៅពីនេះ គាត់បានធ្វើឧទ្យានមួយយ៉ាងធំមានរបងយ៉ាងមាំព័ទ្ធជុំវិញ ហើយនៅក្នុងឧទ្យាននោះ គាត់មានចិញ្ចឹមសត្វម្រឹគីម្រិគាគ្រប់បែបគ្រប់យ៉ាង សម្ងាប់ឱ្យព្រះអង្គម្ចាស់ក្សត្របរបាញ់លេងតាមពេលសព្វព្រះទ័យ ។

កាលបើផ្ទះគាត់បានសង់ហើយស្រេចទាំងអស់ សមនឹងនៅបានស្រួលហើយ. នាយតម្រួតសួនក៏ចូលទៅក្រាបថ្វាយបង្គំព្រះបាទស៊ុលតង់ សុំព្រះរាជានុញ្ញាតឱ្យគាត់លាឈប់ពីតំណែងធ្វើការ ។ នៅពេលនោះ គាត់បាននិយាយទូលព្រះរាជាថា គាត់បានធ្វើការបម្រើព្រះរាជវាំងមកអស់ពេលយូរណាស់ហើយ ឥឡូវគាត់មានវ័យចាស់ជរាហើយពុំអាចធ្វើការបម្រើព្រះអង្គឱ្យបានជិតដល់ទៀតទេ រួចគាត់ក៏ថ្វាយពាក្យសុំលាឈប់នោះទៅព្រះមហាក្សត្រ ទើបថយចេញមក ។ ព្រះបាទស៊ុលតង់ក៏ទ្រង់ព្រះរាជទានឱ្យគាត់លាឈប់ពីតំណែងដោយរីក-រាយ ។ ព្រះអង្គទ្រង់សព្វព្រះទ័យនឹងមុខការគាត់នេះណាស់ តាំងតែពីនៅក្នុងរាជ្យបិតាព្រះអង្គ ក៏ដូចជាតាំងតែពីពេលដែលព្រះអង្គទ្រង់ឡើងសោយរាជ្យសម្បត្តិមកដែរ ។ មួយចំណែកទៀត ព្រះបាទស៊ុលតង់ទ្រង់មានព្រះបន្ទូលថា តើព្រះអង្គមានអ្វីនឹងជូនគាត់ជារង្វាន់ គាត់ក៏ឆ្លើយតបថា : "បពិត្រព្រះករុណាថ្លៃវិសេស ទូលព្រះបង្គំជាខ្ញុំមានសេចក្ដីឆ្អែតឆ្អន់ពេញចិត្តនឹងការធ្វើល្អ របស់ព្រះអង្គនិងបិតាព្រះអង្គណាស់ទៅហើយ ដូច្នេះទូលព្រះបង្គំជាខ្ញុំគ្មានត្រូវការអ្វីទៀត ក្រៅពីប្រាថ្នាសុំឱ្យបានស្លាប់ទៅ ដោយសេចក្ដីរីករាយដូច្នេះទៀត" ។ នាយតម្រួតសួនក៏ថ្វាយបង្គំលា ព្រះបាទស៊ុលតង់ក្សួសារួចបន្ទាប់ពីនោះមកគាត់ក៏ទៅនៅផ្ទះថ្មី ជាមួយនឹងព្រះអង្គម្ចាស់បាម៉ាន. ព្រះអង្គម្ចាស់ប៉ែវីសនិងព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ។ ចំណែកប្រពន្ធគាត់វិញ. នាងបានទទួលអនិច្ចកម្មចំនួនជាពីរបីឆ្នាំមកហើយ ។ លោកនាយកតម្រួតសួននេះទៀត. ក្រោយពីបានរស់នៅរួមសុខទុក្ខជាមួយនឹងបុត្រចិញ្ចឹមបានចំនួនជា ៥ ឬ៦ខែ ក៏ជំងឺទន់ហន់បាននាំស្ដេចមច្ចុរាជមកផ្ដាច់ជីវិតគាត់ទៅទៀត ដោយឥតទុកពេលឱ្យគាត់បាននិយាយរឿងពិតពីរឿងកំណើតនៃបុត្រគាត់ ប្រាប់បុត្រគាត់ទាន់ឡើយ ។ ការនេះគាត់បម្រុងនឹងនិយាយប្រាប់បុត្រគាត់ ព្រោះជាការចាំបាច់ដើម្បីបង្គំព្រះអង្គម្ចាស់ទាំងឡាយឱ្យបន្តការរស់នៅឱ្យបានប្រពៃ ដូចដែលបានធ្វើមកទល់សព្វថ្ងៃនេះ ឱ្យសមទៅតាមភាពនឹងឋានៈនិងឱ្យសមទៅតាមការអប់រំដែលគាត់បានខំខ្នះខ្នែង ហ្វឹកហ្វឺនបង្ហាត់បង្ហាញទូន្មានអស់ពេលជាយូរមកហើយផង ។



ព្រះអង្គម្ចាស់បាម៉ាន ព្រះអង្គម្ចាស់ប៉ែវីសព្រមទាំងព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ដោយទ្រង់គ្មានស្គាល់បិតាឯណាក្រៅពីនាយតម្រួតសួន ក៏ទ្រង់សោកស្ដាយនាយតម្រួតសួនហាក់ដូចជាបិតាព្រះអង្គបង្កើតហើយព្រះអង្គទ្រង់បំពេញកិច្ចផ្សេង១សព្វគ្រប់ទាំងអស់ក្នុងពេលបូជាសពនាយតម្រួតសួន សមទៅតាមសេចក្ដីស្នេហានិងសេចក្ដីកតញ្ញូដែលបុត្រត្រូវមានចំពោះមាតាបិតា ។ ដោយហេតុតែនាយតម្រួតសួនបានស្លាប់ទៅ. នៅសល់ទ្រព្យសម្បត្តិជាច្រើនទុកជូនបុត្រចិញ្ចឹមរបស់គាត់. ព្រះអង្គម្ចាស់ទាំងឡាយក៏ទ្រង់សព្វព្រះទ័យនឹងរបស់មរតកនេះណាស់ ហើយទ្រង់ក៏បន្តការរស់នៅជាមួយគ្នាដូច្នេះតរៀងទៅ. ឥតមានព្រះទ័យលោភលន់ចង់បានអ្វីទៀតឡើយ ។

ថ្ងៃមួយ. នៅពេលដែលព្រះអង្គម្ចាស់ព្រះរៀមទាំងពីរយាងទៅបរបាញ់. ហើយព្រះអង្គម្ចាស់ក្សត្រីទ្រង់នៅចាំផ្ទះមានស្រីអ្នកកាន់សាសនាអ៊ីស្លាមម្នាក់មានវ័យចាស់ណាស់ទៅហើយ បានដើរមកឈរនៅមាត់ទ្វារផ្ទះ ហើយអង្វរសុំឱ្យគេអនុញ្ញាតឱ្យគាត់ចូលសូត្រធម៌បន្តិច ព្រោះដល់ពេលត្រូវសូត្រធម៌ ។ គេក៏ទៅទូលសុំសេចក្ដីអនុញ្ញាតពីព្រះនាងម្ចាស់ក្សត្រី ។ ព្រះអង្គម្ចាស់ក្សត្រីក៏បង្គាប់ឱ្យគេបើកទ្វារឱ្យស្រីនោះចូល ហើយបង្ហាញកន្លែងសូត្រធម៌គាត់ ដែលនាយតម្រួតសួនឥតធ្វេសប្រហែសបានធ្វើបន្ទប់ជាប់នឹងផ្ទះធំ ព្រោះទីនោះគ្មានព្រះវិហារអ៊ីស្លាម ។ ក្រៅពីនេះព្រះនាងទ្រង់មានសវនីយ៍បង្គាប់ដូច្នេះទៀតថា កាលបើស្រីអ្នកកាន់សាសនានោះសូត្រធម៌ចប់ហើយ ត្រូវនាំគាត់ដើរមើលផ្ទះនឹងទីសួន រួចហើយនាំគាត់មកជួបនឹងព្រះនាងបន្តិច ។

ស្ត្រីអ្នកកាន់ធម៌ក៏ដើរចូលទៅ. ហើយចូលទៅសូត្តធម៌ក្នុងកន្លែងដែលគេបានបង្ហាញគាត់ ។ លុះគាត់សូត្រធម៌ចប់ ភិលៀងម្ចាស់ក្សត្រីពីរនាក់. ដែលនៅឈរចាំគាត់ ក៏អញ្ជើញគាត់ឱ្យដើរមើលផ្ទះនឹងទីសួន។ គាត់ក៏យល់ព្រមតាម. ភិលៀងទាំងពីរក៏នាំជូនចាស់ដើរមើលផ្ទះពីបន្ទប់មួយទៅបន្ទប់មួយ. ហើយនៅគ្រប់បន្ទប់គាត់បានសម្លឹងមើលរបស់សព្វគ្រប់ទាំងអស់ ។ បន្ទាប់មកភិលៀងក៏នាំគាត់ចូលទៅក្នុងទីសួន. គាត់ក៏បានឃើញរបៀបគំនូរថ្មីប្លែក. គាត់ក៏ស្ងើចក្នុងចិត្ត. ហើយនិយាយថា អ្នកដែលបានគូរគំនូរឱ្យគេធ្វើនេះ ប្រាកដជាគ្រូសិល្ប៍



យ៉ាងចំណាន ។ នៅទីបំផុត. ស្រីអ្នកកាន់សាសនានោះក៏បានចូលទៅជួបនឹងព្រះអង្គម្ចាស់ក្សត្រី ដែលគង់នៅក្នុងបន្ទប់ទទួលភ្ញៀវ ។ បន្ទប់នេះមានលម្អនឹងគ្រឿងតុបតែងឆើតជាងបន្ទប់មុនៗ ដែលស្រីអ្នកកាន់ធម៌បានឃើញ ។

កាលបើព្រះអង្គម្ចាស់ក្សត្រីបានឃើញស្ត្រីអ្នកកាន់សាសនាដើរចូលមកភ្លាម. ព្រះអង្គម្ចាស់ក៏មានសវនីយទៅកាន់ស្រីនោះភ្លាមថា : “ជីដូនថ្លៃ សូមជីដូនអញ្ជើញមកជិត. ហើយអញ្ជើញមកអង្គុយក្បែរខ្ញុំឯនេះ ។ ខ្ញុំមានសេចក្ដីត្រេកអរនិងសុភមង្គល ដែលឱកាសល្អបានផ្ដល់ឱ្យខ្ញុំមានពេលបាននិយាយសន្ទនាជាមួយមនុស្ស ដូចជាជីដូននេះ ដែលដែលបានដើរផ្លូវត្រូវផ្លូវល្អ ព្រោះបានប្រគល់ខ្លួនទាំងអស់ចំពោះព្រះអាទិទេព. ហើយដែលជនទាំងអស់ត្រូវតែយកតម្រាប់តាម បើសិនជាខ្លួនជាអ្នកប្រកបដោយគតិបណ្ឌិតមែន” ។

ស្ត្រីអ្នកកាន់សាសនាក៏អង្គុយនៅប្របេះខាងកៅអីវែង ប៉ុន្តែព្រះអង្គម្ចាស់ក្សត្រីមិនព្រមឱ្យគាត់អង្គុយដូច្នោះឡើយ ។ ព្រះនាងទ្រង់យាងក្រោកពីកន្លែង ហើយយាងទៅដឹកដៃគាត់ឱ្យអង្គុយជិតព្រះនាង. ត្រង់កន្លែងកិត្តិយស ។ ស្ត្រីអ្នកកាន់សាសនាក៏រំភើបញាប់ញ័រនឹងសេចក្ដីគួរសមនេះណាស់ ទើបគាត់និយាយថា : “អ្នកស្រី. ខ្ញុំមិនសមនឹងទទួលបដិសណ្ឋារកិច្ចដល់ទៅយ៉ាងនេះទេ ហើយដែលខ្ញុំគោរពធ្វើតាមអ្នកស្រីនេះ. ក៏ព្រោះតែអ្នកស្រីបានបង្គាប់មកខ្ញុំ និងដោយ

សារតែអ្នកស្រីជាចៅហ្វាយលើទីនេះផង" ។ កាលបើស្រីអ្នកកាន់សាសនាអង្គុយចុះ ហើយមុននឹងចាប់ពិភាក្សាគ្នាភិលៀងព្រះអង្គម្ចាស់ក្សត្រីម្នាក់បានលើកថាសតូចល្មមដាក់នំ, ផ្លែឈើក្នុងរដូវដំណាប់ផ្លែឈើ និងបង្អែមកំប៉ុងមកថ្វាយព្រះនាងនិងជូនដូនចាស់នោះ ។

ព្រះអង្គម្ចាស់ក្សត្រី ទ្រង់ចាប់យកនំមួយចានជូនទៅដូនចាស់ ហើយទ្រង់មានសវនីយថា : "ជីដូនថ្លៃ, សូមជីដូនទទួលយកពិសាទៅ រួចរើសយកផ្លែឈើណាដែលជីដូនពេញចិត្តពិសាទៀតទៅ" ។ ជីដូនប្រាកដជាត្រូវការទទួលទានហើយ បន្ទាប់ពីជីដូនបានធ្វើដំណើរមកដល់ទីនេះ ។ ដូចចាស់ក៏ឆ្លើយថា : "អ្នកស្រី, ខ្ញុំពុំដែលទម្លាប់ទទួល-ទានរបស់ដ៏ឆ្ងាញ់ៗដូច្នេះសោះ, ហើយបើសិនជាខ្ញុំទទួលទាន គឺមកពីខ្ញុំមិនហ៊ានប្រកែកនឹងទទួលយករបស់អ្វីៗដែលព្រះអាទិទេពលោកបានផ្ញើមកឱ្យខ្ញុំតាមដៃនៃអ្នកសប្បុរសដូចជាអ្នកស្រីនេះ ។

នៅពេលដែលដូនចាស់កំពុងទទួលទានរបស់ផ្សេងៗ ព្រះអង្គម្ចាស់ក្សត្រី ដែលកំពុងសោយរបស់ផ្សេងៗដែរ ដើម្បីកំដរដូនចាស់ បានមានសវនីយសួរទៅដូនចាស់ជាច្រើនអំពីការហាត់ពត់ចិត្តប្រព្រឹត្តតាមសាសនា ដែលគាត់បានប្រតិបត្តិមក និងអំពីរបៀបដែលគាត់រស់នៅ។ ដូនចាស់ក៏បានឆ្លើយតបទៅព្រះនាងក្សត្រីវិញ ដោយសេចក្តីសុភាព។ លុះជជែកគ្នាពីនេះពីនោះបានបន្តិចទៅ, ព្រះអង្គម្ចាស់ក្សត្រីក៏សួរទៅដូនចាស់ថា តើគាត់យល់ឃើញដូចម្តេចអំពីគេហស្ថានព្រះនាងនេះ ។



ស្រីអ្នកកាន់សាសនាក៏ឆ្លើយថា : "អ្នកស្រីផ្ទះនេះល្អណាស់ មើលទៅគួរឱ្យសប្បាយ, មានគ្រឿងតាំងយ៉ាងល្អឆើត មើលទៅគ្មានឱ្យទាស់ត្រង់ណា។ ឯទីកន្លែងវិញគឺផ្ទះនេះបានសង់នៅលើកន្លែងត្រជាក់ត្រជុំកើតកាលវាលគុម្ពជាប្រាកដ ហើយគេពុំអាចរកសួនច្បារឯណាទៀតឱ្យបានសប្បាយជាងនេះបានឡើយ" ។ ប៉ុន្តែបើសិនជាអ្នកស្រីអនុញ្ញាតឱ្យខ្ញុំនិយាយឱ្យអស់កុំឱ្យមានសល់អ្វីនោះៗ ខ្ញុំសូមជម្រាបថាផ្ទះនេះនឹងទៅជាផ្ទះមួយល្អរកប្រៀបគ្មាន បើសិនជាអ្នកស្រីអាចរករបស់បីមុខ ដែលនៅខ្វះមកដាក់បំពេញទៀតបាន, នេះតាមយោបល់ខ្ញុំ ។

- ជីដូន ព្រះអង្គម្ចាស់ក្សត្រីបារីសាដមានសវនីយ, តើអ្វីខ្លះទៅរបស់បីមុខនោះ? សូមជីដូនមេត្តាប្រាប់ខ្ញុំមក ខ្ញុំសូមអង្វរដោយតាងនាមព្រះអាទិទេព ។ ខ្ញុំនឹងឥតសំចៃកម្លាំងឡើយ ដើម្បីនឹងរករបស់នោះឱ្យបាន, បើសិនជាអាចធ្វើកើត ។

- អ្នកស្រី, ដូនចាស់រៀបរាប់, របស់ទីមួយគឺបក្សាចេះនិយាយ គឺជាបក្សាមួយចម្លែកឈ្មោះប៊ុលប៊ុលហឹសារ ហើយប្រកបដោយលក្ខណៈចេះល្បួងហៅបក្សាបក្សីនៅទីជិតខាង ដែលកំពុងស្រែកឱ្យស្រែកតាមសម្រែកខ្លួន ។ របស់ទីពីរគឺដើមឈើចេះច្រៀង ដែលមានស្លឹកទាំងឡាយទុកដូចជាមាត់ ហើយអាចប្រគុំកើតជាភ្លេងមានសម្លេងប្លែកៗ, ហើយសម្លេងតន្ត្រីនេះឥតចេះឈប់សោះឡើយ។ នៅទីបំផុត

របស់ទីបី គឺទឹកពណ៌លឿងដូចពណ៌មាស ហើយទឹកនេះ កាលបើគេយកទៅចាក់តែមួយដំណក់ចូលទៅក្នុងអាងទឹកមួយ ដែលទើបនឹងធ្វើហើយនៅក្នុងទីសួននេះ ឬនៅកន្លែងណាក៏ដោយនឹងរីកទំហំឡើងពេញអាង ហើយកើតរាងទៅជាកណ្ដាប់ស្រូវមួយដុះចេញឡើង ពីកណ្ដាលអាងនោះ ។ ទឹកផុះជាកណ្ដាប់ស្រូវនេះ តែងហូរបាញ់ឡើងលើ ហើយធ្លាក់ចុះទៅក្នុងអាងវិញឥតឈប់ឈរ ដោយឥតឱ្យហៀរទឹកចេញពីអាងនោះឡើយ ។

- អែយ៉ា ! ជីដូនថ្លៃ, ព្រះអង្គម្ចាស់ក្សត្រីទ្រង់ផ្ទះសម្រែក, តើខ្ញុំត្រូវដឹងគុណជីដូនយ៉ាងណាទៅ ដែលជីដូនបានប្រាប់វត្ថុនោះដល់ខ្ញុំ ! របស់ទាំងនេះគួរឱ្យខ្ញុំចង់ឃើញណាស់, ហើយខ្ញុំពុំដែលឮគេនិយាយសោះថា នៅក្នុងលោកនេះ មានរបស់ដ៏ចម្លែកអស្ចារ្យដូច្នេះឡើយ ។ ប៉ុន្តែ ដោយខ្ញុំជឿថាជីដូនប្រាកដជាស្គាល់ទីកន្លែងវត្ថុទាំងនោះហើយដូច្នេះ ខ្ញុំនឹងនៅចាំស្ដាប់ជីដូនមានប្រសាសន៍ប្រាប់ខ្ញុំពីរឿងនេះតទៅទៀត ។

ដើម្បីបំពេញសេចក្ដីត្រូវការរបស់ព្រះអង្គម្ចាស់ក្សត្រី ស្រីអ្នកកាន់សាសនាក៏ពោលថា : "អ្នកស្រី, ខ្ញុំនឹងទៅជាមនុស្សមិនសមនឹងត្រូវបានអ្នកស្រីទទួលឱ្យសំណាក់អាស្រ័យ ដោយសេចក្ដីសប្បុរសដូច្នេះទេ បើសិនជាខ្ញុំហើយប្រកែកមិនព្រមបំពេញសេចក្ដីត្រូវការដែលអ្នកស្រីប្រាថ្នាចង់ដឹង ។ ដូច្នេះ ខ្ញុំមានសេចក្ដីរីករាយនឹងជម្រាបអ្នកស្រីថា



វត្ថុបីមុខដែលខ្ញុំទើបតែនឹងនិយាយជម្រាបអ្នកស្រីនោះ ស្ថិតនៅត្រង់កន្លែងជាមួយគ្នា ត្រង់ទីព្រំដែននៃព្រះរាជអាណាចក្រខាងទិសប្រទេសឥណ្ឌា ។ ផ្លូវដែលត្រូវទៅកាន់កន្លែងនោះ កាត់តាមមុខផ្ទះអ្នកស្រីនេះ ។ មនុស្សណាដែលអ្នកស្រីចាត់ឱ្យទៅកាន់កន្លែងនោះ ត្រូវដើរតែតាមផ្លូវនេះចំនួនម្ភៃថ្ងៃ ហើយនៅថ្ងៃទីម្ភៃមួយ អ្នកនោះឯងត្រូវសួរជនណាដែលខ្លួនបានជួបដំបូងបង្អស់ថា តើបក្សាចេះនិយាយ ដើមឈើចេះច្រៀង, នឹងទឹកពណ៌លឿងនៅឯណា? គេនឹងនិយាយប្រាប់ពុំខាន" ។ កាលបើនិយាយចប់ភ្លាម ជួនចាស់នោះក៏ក្រោកឡើង, ហើយក្រោយពីបានជម្រាបលាព្រះអង្គម្ចាស់ក្សត្រី, គាត់ក៏ថយចេញទៅបន្តដំណើរគាត់ទៅទៀត ។

ព្រះនាងប៉ារីសាដ មានព្រះទ័យកង្វល់រំពល់ជាក្រៃលែងនឹងរក្សាកត់ត្រាទុកកុំឱ្យមានភ្លេច នូវសេចក្ដីត្រូវការរបស់អ្នកស្រីកាន់សាសនាអ៊ីស្លាមអំពីរឿងបក្សាចេះនិយាយ, រុក្ខជាតិចេះច្រៀង, នឹងទឹកពណ៌លឿងនេះ ព្រោះព្រះនាងបានស្មានខុសថា ស្រីអ្នកកាន់សីលនឹងលាចេញពីទីនេះទៅ លុះណាតែបន្ទាប់ពីព្រះនាងបានសួរបញ្ជាក់គាត់ពីរឿងខាងលើនេះសព្វគ្រប់សិន ។ អាស្រ័យហេតុនេះ ព្រះនាងហាក់ដូចជាពុំអស់ក្នុងព្រះទ័យសោះ ដោយហេតុថា ការដែលព្រះនាងបានស្ដាប់ឮពីមាត់ស្រីអ្នកកាន់សីលទាំងប៉ុន្មាន ដូចជាពុំទាន់គ្រប់គ្រាន់សោះ ដើម្បីកុំឱ្យរងគ្រោះថ្នាក់ឥតអំពើ ដោយសារតែការធ្វើដំណើរ

ទៅគ្មានបានផលអ្វី ។ ព្រះនាងមិនមែនចង់ឱ្យគេរត់ទៅតាមគាត់ ដើម្បីហៅគាត់ឱ្យត្រឡប់មកវិញទេ. ប៉ុន្តែ ព្រះនាងខំតាំងស្មារតី ដើម្បីនឹកឱ្យឃើញទាំងអស់នៅការអ្វីៗទាំងប៉ុន្មាន ដែលព្រះអង្គបានឮ ហើយខំធ្វើយ៉ាងណាកុំឱ្យភ្លេចទៅវិញ ។ កាលបើព្រះនាងយល់ថា ព្រះនាងបានកត់ត្រាចំណាំចាំក្នុងព្រះទ័យឥតមានសល់សោះឡើយ. ព្រះនាងក៏ទ្រង់នឹកសង្ឃឹមយ៉ាងមាំថា នឹងបានឃើញការសប្បាយយ៉ាងអស្ចារ្យពុំខាន បើសិនជាព្រះនាងអាចរករបស់ដ៏អស្ចារ្យទាំងនោះបានដូចសេចក្តីប្រាថ្នាមែន ។ ប៉ុន្តែឧបសគ្គដែលព្រះនាងទ្រង់យល់ដល់ក្នុងរឿងនោះ និងសេចក្តីបារម្ភខ្លាចពុំបានសម្រេចតាមព្រះទ័យ បានធ្វើឱ្យព្រះនាងព្រួយព្រះចិន្តាជាក្រៃលែង ។

ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដកំពុងតែឈ្លក់ព្រះទ័យក្នុងរឿងនេះ ស្រាប់តែព្រះអង្គម្ចាស់ ព្រះរៀមយាងត្រឡប់មកដល់ពីបរបាញ់សត្វវិញ។ ព្រះអង្គម្ចាស់ទាំងពីរក៏យាងចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ ហើយស្រាប់តែទតឃើញព្រះនាងមានទឹកព្រះភក្ត្រស្រពាប់ស្រពោនខុសពីប្រក្រតី. ព្រះនាងទ្រង់ឱនព្រះភក្ត្រចុះដូចជាកើតទុក្ខធំណាស់ ឥតងើបព្រះភក្ត្រឡើងបន្តិច គ្រាន់ជាសញ្ញាឱ្យដឹងថា ព្រះនាងបានទតឃើញព្រះអង្គដែរឡើយ ។ ព្រះអង្គម្ចាស់បាម៉ានក៏មានព្រះបន្ទូលថា: “ម្ចាស់អូន. តើសេចក្តីសប្បាយរីករាយ ដែលធ្លាប់តែមានជាប់ជានិច្ចជាមួយម្ចាស់អូនឯង របូតមកទល់នឹងសព្វថ្ងៃនេះ រត់ទៅឯណាទៅ? ម្ចាស់



អូនមិនស្រួលខ្លួនឬ? មានគ្រោះថ្នាក់អ្វីកើតមានដល់អូនឬ? មានគេប្រាប់រឿងអ្វីនាំឱ្យលំបាកចិត្តឬ? សូមម្ចាស់អូនប្រាប់មកយើង ជាព្រះរៀមកុំលាក់ឱ្យសោះ ដើម្បីឱ្យព្រះរៀមចូលរួមក្នុងរឿងនោះ ផងហើយនឹងគិតរកឱសថមកដាក់ឱ្យត្រូវ. ឬមួយក៏ព្រះរៀមនឹងសងសឹកជំនួសម្ចាស់អូន បើសិនជានរណាហើយមានចិត្តព្រហើនប្រមាថមើលងាយមនុស្សដូចជាម្ចាស់អូននេះ ដែលគេត្រូវតែមានសេចក្តីគោរព” ។

ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ក៏ទ្រង់គង់នៅស្ងៀមយ៉ាងយូរគ្មានមានព្រះសវនីយ៍ឆ្លើយតបនឹងព្រះរៀមថាដូចម្តេចឡើយ ។ នៅទីបំផុត ព្រះនាងក៏ទ្រង់ងើបព្រះភក្ត្រឡើង ទតទៅព្រះរៀមទាំងពីរហើយទ្រង់អោនចុះវិញមួយរំពេច. បន្ទាប់ពីមានព្រះសវនីយ៍ទូលព្រះរៀមថា គ្មានរឿងអ្វីទេ ។

ព្រះអង្គម្ចាស់បាម៉ាន ក៏មានព្រះបន្ទូលតទៅទៀតថា: “ម្ចាស់អូន. ម្ចាស់អូនលាក់ការពិតនឹងព្រះរៀមហើយ ប្រាកដជាមានរឿងអ្វីពុំខាន ហើយជារឿងធំផង ។ វាមិនសមសោះនៅក្នុងរយៈពេលដ៏ខ្លីដែលព្រះរៀមបានបែកពីម្ចាស់អូនទៅមានកើតហេតុយ៉ាងធំ បើតាមព្រះរៀមបានសង្កេតឃើញអាកប្បកិរិយាម្ចាស់អូន. ហើយម្ចាស់អូនមានបន្ទូលបញ្ជាក់ថាគ្មានរឿងអ្វីទេ ។ ម្ចាស់អូនស្មានថា ព្រះរៀមមិនអភ័យទោសឱ្យម្ចាស់អូនឬ បើសិនជាចម្លើយម្ចាស់អូនបណ្តាលឱ្យព្រះរៀមពុំសប្បាយចិត្ត ។ ដូច្នេះត្រូវម្ចាស់អូនកុំលាក់នឹងព្រះរៀម លុះត្រា

តែព្រះវៀមអាចសន្និដ្ឋានបានថា ម្ចាស់អូនចង់ឈប់ចងស្ពានមេត្រីនិងរស់នៅជាមួយគ្នាយ៉ាងស្និទ្ធស្នាលតទៅទៀតនោះ ដែលជាអំពើដែលយើងធ្លាប់មានមកទល់នឹងថ្ងៃនេះ ចាប់តាំងពីនៅជាកុមារភាពម្ល៉េះ” ។

ព្រះអង្គម្ចាស់ក្សត្រី ដែលគ្មានព្រះទ័យនឹងចង់ផ្ដាច់ភាតរភាពជាមួយនឹងព្រះវៀមសោះ ក៏មានព្រះសវនីយ៍ឡើងថា : “កាលដែលម្ចាស់អូនបាននិយាយទូលព្រះវៀមថា ម្ចាស់អូនគ្មានរឿងអ្វីទេនោះៗ ម្ចាស់អូននិយាយចំពោះទៅនឹងខ្លួនព្រះវៀម មិនមែននិយាយចំពោះខ្លួនម្ចាស់អូនទេ ដែលយល់ថារឿងនេះជាការមានប្រយោជន៍ខ្លះ ។ ឥឡូវដោយម្ចាស់ព្រះវៀមទ្រង់ចុចទៅលើរឿងភាតរភាព និងការរួបរួមគ្នា ដែលជាទីស្រឡាញ់បំផុតរបស់ម្ចាស់អូននោះៗម្ចាស់អូននឹងនិយាយទូលព្រះវៀមអំពីរឿងនោះ ។ ម្ចាស់ព្រះវៀមក៏យល់ដូចជាម្ចាស់អូនដែរថា ផ្ទះនេះដែលជាកេរ្តិ៍បិតាយើងបានសង់ទុកឱ្យ មានតុបតែងលម្អដោយក្បាច់និងគ្រឿងសង្ហារិមហើយស្រេចសព្វគ្រប់ទាំងអស់គ្មានខ្វះចន្លោះត្រង់កន្លែងណាសោះ ប៉ុន្តែទើបតែនឹងមកដល់ថ្ងៃនេះ ខ្ញុំម្ចាស់ក៏បានដឹងថា ផ្ទះនេះមានខ្វះរបស់បីទៀត បើសិនជាបានរបស់នោះមក នោះផ្ទះនេះនឹងទៅជាល្អដាច់គេរកប្រៀបគ្មាន បណ្ដាផ្ទះទាំងឡាយដែលសង់នៅទីជនបទដូចគ្នា ក្នុងលោកយើងនេះ។ របស់ទាំងបីនោះគឺបក្សាចេះនិយាយ. ដើមឈើចេះច្រៀង និងទឹកពណ៌លឿងដូច-ជាពណ៌មាស” ។



បន្ទាប់ពីបានមានសវនីយ៍ទូលព្រះវៀមអំពីវត្ថុល្អនោះ ព្រះអង្គម្ចាស់ក្សត្រីក៏ទ្រង់បន្ថែមថា : “គឺអ្នកស្រីកាន់សាសនាអ៊ិស្លាមម្នាក់ដែលបានប្រាប់ម្ចាស់អូនអំពីរឿងនេះ អំពីទីកន្លែងដែលវត្ថុទាំងនោះស្ថិតនៅ ព្រមទាំងផ្លូវដែលទៅកាន់ទីនោះ ។ ម្ចាស់ព្រះវៀមប្រហែលជាយល់ឃើញថា របស់ទាំងនោះមិនជាមានសារៈសំខាន់ប៉ុន្មានទេដើម្បីយកមកតុបតែងផ្ទះយើងឱ្យបានល្អសព្វគ្រប់ ហើយអាចនៅតែល្អដាច់គេដរាប ព្រោះតែមានរបស់ថ្មីនេះមកបន្ថែមនោះទេ ។ ម្ចាស់អូនសូមទុកឱ្យព្រះវៀមយល់ឃើញយ៉ាងណាក៏យល់ចុះ ប៉ុន្តែ ម្ចាស់អូនពុំអាចនៅស្ងៀមមិននិយាយទូលព្រះវៀមបានឡើយថា ចំណែកម្ចាស់អូនៗយល់ថា របស់នោះជាការមានប្រយោជន៍ចាំបាច់ដល់ផ្ទះយើង ហើយម្ចាស់អូននឹងឥតសប្បាយចិត្តសោះឡើយ បើសិនជាម្ចាស់អូនពុំបានឃើញរបស់ទាំងនោះមកដាក់តាំងក្នុងទីនេះ ។ ដូច្នេះទោះព្រះវៀមយល់ថាគ្មានប្រយោជន៍ឬមានក៏ដោយ. ក៏ម្ចាស់អូនសូមឱ្យព្រះវៀមជួយឱ្យដំបូន្មាននិងជួយគិតមើលថា តើម្ចាស់អូនត្រូវចាត់នរណាឱ្យទៅរកយករបស់នោះឱ្យបាន ។

- ម្ចាស់អូន. ព្រះអង្គម្ចាស់បាម៉ានមានបន្ទូល គ្មានអ្វីដែលម្ចាស់អូនត្រូវការហើយៗម្ចាស់ព្រះវៀមឥតត្រូវការផងដែរនោះទេ ។ ដែលម្ចាស់ព្រះវៀមពោលនេះ ព្រោះឃើញម្ចាស់អូនមានការរវៀសរវៃក្នុងរឿងនេះពេក ដើម្បីឱ្យម្ចាស់បងចូលរួមក្នុងរឿងនេះផង ។ ប៉ុន្តែផ្ទុយ

អំពីគំនិតម្ចាស់អូនយល់ទៅវិញ. ម្ចាស់ព្រះវរៀមក៏ចង់បានរបស់នោះដូចជាម្ចាស់អូនដែរ ព្រោះម្ចាស់ព្រះវរៀមជឿជាក់ថា ម្ចាស់អូនក៏ឥតមានមនោសញ្ចេតនាប្លែកពីម្ចាស់បងដែរ ។ ដូច្នេះ គឺយើងទាំងពីរនាក់នេះហើយ ដែលត្រូវចេញទៅធ្វើការច្បាំងដណ្ដើមរបស់នេះមកប្រើ ព្រោះម្ចាស់អូនបានហៅដូច្នេះ ហើយឱ្យសមនឹងតម្លៃវត្ថុដែលយើងត្រូវទៅរកនោះផង ។ ព្រះវរៀមក៏សុំខ្លួនទៅរករបស់នោះ សូមម្ចាស់អូនគ្រាន់តែនិយាយប្រាប់ព្រះវរៀមមកអំពីផ្លូវដែលត្រូវទៅ និងទីកន្លែងនៃរបស់នោះ ព្រះវរៀមនឹងចេញដំណើរទៅមិនឱ្យយូរហួសពីថ្ងៃស្អែកនេះឡើយ ។

- ម្ចាស់ព្រះវរៀម, ព្រះអង្គម្ចាស់ប៉ែរីសជាព្រះអនុជបន្ទាប់មានព្រះបន្ទូល, ម្ចាស់ព្រះវរៀមជាចៅហ្វាយនិងជាទីពំនាក់ក្នុងទីនោះ, ដូច្នេះ មិនសមបើម្ចាស់ព្រះវរៀមធ្វើដំណើរចេញចោលផ្ទះអស់ពេលយ៉ាងយូរដូច្នេះទេ មួយចំណែកទៀតខ្ញុំសូមអង្វរម្ចាស់ក្សត្រីទុកឱ្យខ្ញុំចេញទៅបំពេញបេសកកម្មនេះវិញ ព្រោះខ្ញុំក៏ចេះបំពេញករណីយកិច្ចមិនអន់ថយជាងម្ចាស់ព្រះវរៀមប៉ុន្មានដែរ, ហើយកិច្ចការក្នុងផ្ទះយើងនឹងអាចស្ថិតនៅជាសណ្ដាប់ដដែល ។

- ម្ចាស់អូន, ព្រះវរៀមយល់ច្បាស់ហើយនូវសុឆន្ទៈរបស់ម្ចាស់អូន ហើយម្ចាស់អូនក៏អាចធ្វើដំណើរនេះបានដូចជាព្រះវរៀមដែរ ប៉ុន្តែដោយការនេះបានសម្រេចរួចទៅហើយ ម្ចាស់ព្រះវរៀមបានបម្រុងធ្វើ



ហើយនិងត្រូវតែធ្វើ ។ សូមព្រះអនុជគង់នៅជាមួយនឹងម្ចាស់ក្សត្រីអូនយើងទៅ ហើយព្រះវរៀមឥតចាំបាច់ផ្ដែផ្ដាំអ្វីទៀតទេ” ។ បន្ទាប់ពីនោះមក. ព្រះអង្គម្ចាស់ព្រះវរៀមទ្រង់បានខ្វល់ខ្វាយរៀបចំគ្រឿងប្រដាប់ធ្វើដំណើរ និងសាកសួរព័ត៌មានពីព្រះនាងឱ្យបានជ្រាបច្បាស់សព្វគ្រប់ ដើម្បីកុំឱ្យឃ្លាតចាកពីគោលបំណង ។

ស្អែកឡើងនៅពេលព្រលឹមធំ. ព្រះអង្គម្ចាស់បាម៉ានក៏បានឡើងគង់លើសេះរៀបចំធ្វើដំណើរយាងចេញទៅ ។ ព្រះអង្គម្ចាស់ប៉ែរីសនិងព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ដែលចង់ឃើញព្រះវរៀមធ្វើដំណើរចេញទៅពេក ក៏ស្ទុះទៅឱបរឹតព្រះអង្គ រួចថ្វាយពរសូមព្រះវរៀមធ្វើដំណើរទៅប្រកបដោយសេចក្ដីសុខសប្បាយ ។ ប៉ុន្តែនៅពេលនោះ, ព្រះអង្គម្ចាស់ក្សត្រីក៏ទ្រង់នឹកឃើញរឿងមួយ ទើបព្រះនាងមានសវនីយ៍ទៅកាន់ព្រះវរៀមថា : “ម្ចាស់ព្រះវរៀមម្ចាស់អូនឥតនឹកឃើញដល់គ្រោះថ្នាក់ ដែលអាចកើតមានក្នុងការធ្វើដំណើរនេះទេ តែថាតើនរណាមួយអាចដឹងថា ម្ចាស់អូនពិតជានឹងបានឃើញម្ចាស់ព្រះវរៀមត្រឡប់មកវិញ? សូមម្ចាស់យាងចុះមកសិន, ម្ចាស់អូនសូមអង្វរ ហើយឈប់ធ្វើដំណើរទៅត្រឹមនេះចុះ ម្ចាស់អូនស៊ូរខានឃើញនឹងខានបានបក្សា ចេះនិយាយ ដើមឈើចេះច្រៀង និងទឹកពណ៌លឿងជាជាងនឹងនៅទន្ទឹងតែចាំមើលផ្លូវព្រះវរៀមឥតឈប់ឈរ បារម្ភក្រែងតែមិនឃើញព្រះវរៀមយាងត្រឡប់មកវិញដូច្នេះនោះ ។

- ព្រះអង្គម្ចាស់បាម៉ានមានព្រះបន្ទូលទាំងញញឹម ព្រោះឃើញម្ចាស់ក្សត្រីឆាប់ភ័យអ្វីម្ល៉េះយ៉ាងនេះថា ម្ចាស់ក្សត្រីអូន. ការសម្រេចចិត្តបានធ្វើរួចទៅហើយ ហើយបើសិនជាពេលនេះព្រះរៀមពុំបានធ្វើក៏គង់ពេលក្រោយព្រះរៀមនៅតែទទូចធ្វើឱ្យទាល់តែបានទៀតដែរ ។ ដូច្នោះសូមម្ចាស់ក្សត្រីអូនអនុញ្ញាតឱ្យម្ចាស់បងធ្វើទៅ ។ គ្រោះថ្នាក់ដែលម្ចាស់អូនបាននិយាយនោះកើតមានឡើងតែដល់ពួកអភព្វបុគ្គលទេ ។ ពិតមែនហើយ. ម្ចាស់ព្រះរៀមក៏អាចចាត់ចូលជាមួយពួកជនអភព្វនោះដែរ ប៉ុន្តែម្ចាស់ព្រះរៀមក៏អាចចាត់ចូលជាមួយនឹងពួកភព្វបុគ្គល ដែលមានចំនួនច្រើនជាងអភព្វបុគ្គល ។ ប៉ុន្តែដោយហេតុថាព្រឹត្តិការណ៍ទាំងឡាយមិនមែនសុទ្ធតែពិតប្រាកដនោះទេ ហើយម្ចាស់ព្រះរៀមក៏អាចស្លាប់បាន ក្នុងការធ្វើដំណើរនេះដែរ ដូច្នេះការដែលព្រះរៀមអាចធ្វើបាន គឺទុកកាំបិតនេះថ្វាយម្ចាស់ក្សត្រីអូន" ។

នៅពេលនោះព្រះអង្គម្ចាស់បាម៉ានក៏ដកយកកាំបិតស្នៀតព្រមទាំងស្រោមថ្វាយទៅព្រះអង្គម្ចាស់ក្សត្រី រួចមានព្រះបន្ទូលថា: "សូមម្ចាស់អូនទទួលយកទុក. ហើយយូរៗម្ដង សូមម្ចាស់អូនដកកាំបិតនេះចេញពីស្រោមមើល បើសិនជាដកចេញពីស្រោមមកឃើញកាំបិតនេះស្អាតទេ នោះជាសញ្ញាឱ្យដឹងថា ព្រះរៀមទ្រង់មានព្រះជន្មនៅឡើយទេ ប៉ុន្តែបើសិនជាម្ចាស់អូនឃើញស្រក់ឈាមចេញពីមុខកាំបិត នោះជាសញ្ញាឱ្យដឹងថា ម្ចាស់បងអស់ព្រះជន្មហើយៗ សូមម្ចាស់អូនសូត្រធម៌ឧទ្ទិសបញ្ជូនទៅឱ្យផង ។



កាលបើព្រះអង្គម្ចាស់ក្សត្រីបារិសាដ អស់រឿងអ្វីនឹងសុំពីព្រះអង្គម្ចាស់បាម៉ានទៀតហើយ ព្រះអង្គម្ចាស់បាម៉ានក៏មានព្រះបន្ទូលលានាងនឹងព្រះអង្គម្ចាស់ប៉ែរិស ជាលើកក្រោយបំផុត រួចឡើងគង់លើសេះយាងចេញទៅ ប្រកបដោយអាវុធ និងគ្រឿងបរិក្ខាសព្វគ្រប់ ។ ព្រះអង្គក៏ទ្រង់យាងត្រង់តាមផ្លូវគ្មានបែកឆាកទៅខាងស្តាំ ឬខាងឆ្វេងឡើយ. ហើយនៅថ្ងៃទីម្ភៃមួយ. ព្រះអង្គទ្រង់ជួបនឹងតាចាស់ម្នាក់នៅក្បែរផ្លូវ មានរូបរាងអាក្រក់ស្គមស្លៃ ។ តាចាស់នោះអង្គុយនៅក្រោមដើមឈើមួយ ជិតផ្ទះស្បូវមួយ ដែលជាជម្រកសម្រាប់ការពារនឹងការប្រែប្រួលនៃធាតុអាកាស ។

តាចាស់នោះមានរោមចិញ្ចើម. សក់. ពុកមាត់. ពុកចង្កាដូចព្រិល ។ រោមចិញ្ចើមដុះធ្លាក់រហូតមកដល់ចុងច្រមុះ ពុកមាត់គ្របមាត់ជិត ពុកចង្កានិងសក់ធ្លាក់រហូតដល់ជើង ក្រចកដៃក្រចកជើងលូតវែងហួសប្រមាណ មានពាក់អ្វីរាងដូចជាមួកសំប៉ែតហាក់ដូចជាតាំងយូហើយយកកន្ទេលរុំធ្វើជាខោអាវ ។ តាចាស់នោះគឺជាអ្នកបួសក្នុងសាសនាអ៊ិស្លាម គាត់បានបែកចេញពីសង្គមមនុស្ស ដើម្បីទៅរកស្វែងធម៌តែម្នាក់ឯង អស់ពេលជាច្រើនឆ្នាំហើយៗបានធ្វើកិច្ចឧទ្ទិសខ្លួនចំពោះតែព្រះអាទិទេព ដើម្បីនៅទីបំផុតគាត់បានទៅកើតជាព្រះអា-ទិទេពដែរ ។

ព្រះអង្គម្ចាស់បាម៉ាន ដែលបានប្រុងព្រះអង្គតាំងតែពីព្រលឹម



ឱ្យតែបានជួបនរណាម្នាក់ ព្រះអង្គក៏នឹងអាលបានសួរអំពីទីកន្លែងដែលព្រះអង្គប្រាថ្នានឹងយាងទៅនោះ លុះបានជួបតាចាស់នោះកាលណាព្រះអង្គក៏ឈប់យាងចុះពីខ្នងសេះភ្លាម ព្រោះព្រះអង្គយល់ថា អ្នកនេះហើយដែលជាជនទីមួយដែលព្រះអង្គត្រូវសួរព័ត៌មាន ដើម្បីឱ្យត្រូវតាមពាក្យឱ្យការ ដែលស្រីអ្នកកាន់សាសនាបានទូលព្រះអង្គម្ចាស់ក្សត្រីមក ។ ព្រះអង្គម្ចាស់ក៏ទ្រង់ដឹកសេះយាងចូលទៅជិតតាចាស់សម្តែងសេចក្តីគួរសំតាមទម្លាប់ រួចមានព្រះបន្ទូលថា : “លោកតាមានធម៌. ព្រះអាទិទេពបានទុកជីវិតលោកតាឱ្យនៅវែងណាស់ ហើយលោកពេញចិត្តនឹងឱ្យលោកតានៅបំពេញសេចក្តីប្រាថ្នារបស់លោកតា ។

តាចាស់ក៏ឆ្លើយតបនឹងសំនួររបស់ព្រះអង្គម្ចាស់ ប៉ុន្តែព្រះអង្គម្ចាស់ឥតទ្រង់ស្តាប់បានមួយម៉ាត់ឡើយ ។ ដោយហេតុមកពីពុកមាត់គាត់ដុះគ្របមាត់គាត់ជិត ហើយដោយព្រះអង្គម្ចាស់មិនចង់យាងចេញពីទីនោះតទៅទៀត ដោយឥតទាន់បានជ្រាបព័ត៌មាន ដែលព្រះអង្គត្រូវការចង់ដឹងនោះសោះ ព្រះអង្គក៏ហូតយកកន្ត្រៃដែលព្រះអង្គបានដាក់ជាប់ទៅជាមួយចេញមក រួចក្រោយពីបានយកសេះព្រះអង្គទៅចងនឹងមែកឈើមួយ. ព្រះអង្គក៏ទ្រង់មានព្រះបន្ទូលទៅកាន់តាចាស់នោះថា : “លោកតាប្រកបដោយធម៌. ខ្ញុំត្រូវការនិយាយនឹងលោកតាបន្តិច. ប៉ុន្តែឧបសគ្គមកពីពុកមាត់លោកតា ធ្វើឱ្យខ្ញុំស្តាប់លោកតាមានប្រសាសន៍ថាដូចម្តេចពុំបានសោះ ដូច្នេះ ខ្ញុំសូមអង្វរលោកតាសុំឱ្យ

លោកតាអនុញ្ញាតឱ្យខ្ញុំកាត់ពុកមាត់នឹងរោមភ្នែកលោកតាចេញ ដែលជារបស់ធ្វើឱ្យលោកតាមានរូបដូចជាខ្លាឃ្មុំ មិនមែនដូចមនុស្សទេ" ។

អ្នកបួសក៏ឥតយល់ទាស់នឹងបំណងព្រះអង្គម្ចាស់នេះទេ, គាត់យល់ព្រមឱ្យព្រះអង្គម្ចាស់ធ្វើតាមបំណង ។ កាលបើព្រះអង្គម្ចាស់បានកាត់ពុកមាត់ នឹងរោមចិញ្ចើមអ្នកបួសនោះរួចហើយ, ព្រះអង្គក៏ទ្រង់ទតឃើញគាត់មានសាច់ឈាមនៅក្មេងសោះ, មិនមែនចាស់ដូចជាពីពេលព្រះអង្គទតឃើញពីដំបូងសោះ ទើបព្រះអង្គមានព្រះបន្ទូលថា : "លោកតាប្រកបដោយធម៌, បើសិនជាខ្ញុំមានកញ្ចក់ឆ្លុះមុខជាប់មកជាមួយផង ខ្ញុំនឹងជូនឱ្យលោកតាឆ្លុះមើលខ្លួនលោកតា តើលោកតានៅក្មេងស្រស់យ៉ាងណា ។ ឥឡូវនេះ លោកតាទើបពេញជាមនុស្សដែលពីពេលមុននេះ គ្មាននរណាមួយអាចសម្គាល់លោកតាថាជាអ្វីបានឡើយ" ។

ការនិយាយលួងលោមសរសើរខ្លះបញ្ចោរខ្លះនេះ បានធ្វើឱ្យអ្នកបួសញញឹមគោរពតបមកវិញ ហើយនិយាយថា : "លោកម្ចាស់, ទោះលោកម្ចាស់ជានរណាក៏ដោយ, ខ្ញុំត្រូវតែនឹកគុណចំពោះអំពើពិសេសដែលលោកម្ចាស់បានធ្វើដល់ខ្ញុំនេះ ។ ដូច្នេះខ្ញុំបានប្រុងខ្លួនជាស្រេចនឹងបញ្ចេញភស្តុតាងនៃសេចក្ដីកតញ្ញូរបស់ខ្ញុំនេះ ដើម្បីបំពេញកិច្ចអ្វីៗផ្សេង ដែលលោកត្រូវការឱ្យតែការនោះនៅក្រោមអំណាចខ្ញុំនោះៗ លោកម្ចាស់មិនចាំបាច់អញ្ជើញចុះពីខ្នងសេះផង សេចក្ដីត្រូវ



ការនោះ នឹងបានសម្រេចភ្លាម ។ ហេតុនេះសូមលោកម្ចាស់មានប្រសាសន៍ប្រាប់ខ្ញុំមក តើលោកម្ចាស់ត្រូវការអ្វី, ខ្ញុំនឹងខំធ្វើបំពេញចិត្តលោកម្ចាស់ បើសិនជាខ្ញុំអាចធ្វើបាន ។

- លោកតាដ៏ចម្រើន, ព្រះអង្គម្ចាស់បាម៉ានមានព្រះបន្ទូល, ខ្ញុំមកពីទីឆ្ងាយណាស់ ហើយខ្ញុំមកនេះ ត្រូវការរកបក្សាចេះនិយាយ, ដើមឈើចេះច្រៀង និងទឹកពណ៌លឿង ។ ខ្ញុំដឹងថារបស់ទាំងបីមុខនេះស្ថិតនៅទីក្បែរកន្លែងនេះ ប៉ុន្តែខ្ញុំពុំស្គាល់កន្លែងពិតប្រាកដ, បើសិនជាលោកតាដឹង, ខ្ញុំសូមអង្វរមេត្តាបង្ហាញផ្លូវខ្ញុំបន្តិច, ដើម្បីកុំឱ្យខ្ញុំស្ទាក់ស្ទើរពុំដឹងទៅតាមផ្លូវណា ហើយនិងកុំឱ្យខ្ញុំខាតប្រយោជន៍ឥតអំពើបណ្ដាលមកពីការធ្វើដំណើរដ៏ឆ្ងាយនេះ ។

នៅពេលព្រះអង្គម្ចាស់កំពុងមានព្រះបន្ទូលដូច្នេះ ព្រះអង្គទ្រង់សង្កេតឃើញអ្នកបួសផ្លាស់ទឹកមុខ, ឱនក្បាលចុះនៅនឹងថ្កល់មិនមានឆ្លើយថាដូចម្ដេច ត្រឡប់ជានៅស្ងៀមឈឹង ។ ឃើញដូច្នោះ ព្រះអង្គម្ចាស់ក៏មានព្រះបន្ទូលទៀតថា: "លោកតា, ខ្ញុំស្មានហាក់ដូចជា លោកតាបានស្ដាប់ខ្ញុំឮដែរ សូមលោកតាប្រាប់ខ្ញុំមក បើសិនជាលោកតាដឹងឬក៏ពុំដឹងប្រយោជន៍កុំឱ្យខ្ញុំខាតពេល ហើយខ្ញុំនឹងអាចទៅរកសួរគេនៅកន្លែងដទៃទៀត" ។

ទីបំផុត អ្នកបួសក៏ឆ្លើយថា : "លោកម្ចាស់, ផ្លូវដែលលោកម្ចាស់សួរនោះ ខ្ញុំស្គាល់ ប៉ុន្តែ សេចក្ដីរាប់អានដែលខ្ញុំទើបតែនឹងមាន

ជាមួយលោកចាប់តាំងពីកាលខ្ញុំបានឃើញលោកមក. ហើយសេចក្ដីរាប់អាននេះធំជាងកិច្ចដែលលោកម្ចាស់បានធ្វើដល់ខ្ញុំទៀត. បានធ្វើឱ្យខ្ញុំនៅស្ងៀមពុំដឹងថា តើខ្ញុំត្រូវតែបំពេញចិត្តលោកម្ចាស់តាមសេចក្ដីប្រាថ្នារបស់លោកម្ចាស់ឬក៏យ៉ាងណា” ។

តើមានហេតុអ្វីដែលបណ្ដាលឱ្យលោកតារុញរាក្នុងចិត្តដូច្នេះ ឬក៏លោកតាមានឧបសគ្គអ្វីក្នុងការដែលត្រូវប្រាប់ខ្ញុំនេះ. ព្រះអង្គម្ចាស់បាម៉ានទ្រង់សួរ ។

– ខ្ញុំនឹងនិយាយជម្រាបលោកម្ចាស់. អ្នកបួសឆ្លើយ. គឺដោយហេតុមកពីខ្ញុំសម្លឹងឃើញមានគ្រោះថ្នាក់ដែលលោកត្រូវទទួល ហើយលោកនឹងមិនព្រមជឿតាមខ្ញុំ ។ មានពួកអភិជនជាច្រើនដែលមានសេចក្ដីអង់អាចក្លាហានមិនខុសពីលោកម្ចាស់ទេ បានទទួលគ្រោះថ្នាក់នោះរួចមកហើយ ។ ពួកអភិជនទាំងនោះបានធ្វើដំណើរមកតាមនេះ ហើយបានធ្វើសំនួមពរនេះដល់ខ្ញុំដូចជាលោកម្ចាស់ដែរ ។ ហើយខ្ញុំឥតមានធ្វេសប្រហែសនឹងនិយាយពន្យល់ណែនាំអស់លោកទាំងនោះឱ្យបោះបង់សេចក្ដីប្រាថ្នា ហើយយាងទៅរកអ្វីនៅកន្លែងដទៃទៀតទៅ ប៉ុន្តែគេឥតព្រមជឿខ្ញុំសោះ ។ នៅទីបំផុតខ្ញុំក៏ព្រមប្រាប់ផ្លូវ តាមការអង្វររបស់គេ ប៉ុន្តែខ្ញុំសូមបញ្ជាក់ជូនលោកម្ចាស់ឱ្យជ្រាបថា ជនទាំងនោះឥតបានសម្រេចតាមបំណងសោះ ហើយខ្ញុំឥតឃើញសូម្បីតែម្នាក់ត្រឡប់មកវិញឡើយ ហេតុនេះ. ទោះលោកម្ចាស់ស្រឡាញ់ជីវិតលោក



ម្ចាស់តែបន្តិចបន្តួចក្ដី ហើយបើលោកព្រមជឿតាមដំបូន្មានខ្ញុំ សូមលោកម្ចាស់កុំអញ្ជើញទៅឆ្ងាយទៀត ហើយយាងត្រឡប់ទៅគេហស្ថានលោកម្ចាស់វិញទៅប្រសើរជាង” ។

ទោះបីអ្នកបួសបាននិយាយទូលយ៉ាងនេះក៏ដោយ ព្រះអង្គម្ចាស់បាម៉ានក៏នៅតែទទូចចង់ធ្វើតាមព្រះរាជបំណងព្រះអង្គ មិនព្រមជឿតាមអ្នកបួសសោះ ហើយក៏មានព្រះបន្ទូលទៅកាន់អ្នកបួសថា : “ខ្ញុំព្រមជឿថាដំបូន្មានរបស់លោកតានេះស្មោះត្រង់មែន ហើយខ្ញុំត្រូវដឹងគុណលោកតាឥតភ្លេចចំពោះសញ្ញាមិត្តភាព ដែលលោកតាបានតឿនដល់ខ្ញុំនេះ. ប៉ុន្តែទោះជាគ្រោះថ្នាក់ដែលលោកតាបានមានប្រសាសន៍នោះ មានសណ្ឋានយ៉ាងណាក៏ដោយ គ្មានអ្វីអាចធ្វើឱ្យខ្ញុំផ្លាស់គោលបំណងនេះបានឡើយ” ។ បើសិនជាមាននរណាមួយហ៊ានវាយប្រហារខ្ញុំ ក៏ខ្ញុំមានគ្រឿងសាស្ត្រាវុធយ៉ាងសំខាន់នឹងការពារខ្លួនដែរ. ហើយអ្នកនោះឯងក៏មិនមែនក្លាហានខ្លាំងពូកែជាងខ្ញុំប៉ុន្មានដែរ ។

– ចុះបើសិនជាអ្នកដែលវាយប្រហារលោកម្ចាស់. អ្នកបួសបញ្ជាក់. មិនបង្ហាញរូបឱ្យលោកម្ចាស់ឃើញ ហើយវាមានគ្នាច្រើនណាស់ តើលោកម្ចាស់អាចការពារខ្លួនលោកម្ចាស់ទៅនឹងមនុស្សដែលលោកម្ចាស់មើលខ្លួនពុំឃើញនោះម្ដេចបាន?

– អ្វីក៏ដោយ. ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលឆ្លើយយ៉ាងរន្ទើន. ហើយទោះជាលោកតាចេះមានប្រសាសន៍ដូចម្ដេចក៏ដោយ. ក៏